ពូច-អ៊ុម

# វេយ្យាករណ៍ខ្មែរ



វី.62

សំរាប់

ថ្នាក់បឋមសិក្សា

415

ពូច - អ៊ឹម

សាស្ត្រាចារ្យ

# វេយ្យាករណ៍ខ្មែរ

សំរាប់ថ្នាក់

## មជ្ឈិមដ្ឋាន នឹង ឧត្តមដ្ឋាន

បណ្ណាគារ គីម សេង ភ្នំពេញ
លេខ ២២៣ វិថីប្រជាធិបតេយ្យ

បោះពុម្ពលើកទី ៥ ចំនួន ២·០០០ ច្បាប់

ព.ស. ២៥១៥ គ.ស. ១៩៧២

រក្សាសិទ្ធិ

## សារបាន


មាតិកា ទំព័រ

វេយ្យាករណ៍ (អក្សរ - ស្រៈ) ... ១

ព្យញ្ជនៈ ... ២

អក្សរអឃោសៈ-ឃោសៈ-សិថិល ... ៣

តួអក្សរ ... ៤

ព្យញ្ជនៈបន្ថែម - វណ្ណយុត្តិ .... ៥

វិធីប្រើវណ្ណយុត្តិ ... ៦

អក្សរព្យញ្ជនៈផ្លាស់ប្តូររូប ..... ១២

វិធីសាធ្យាយចាំមាត់ ... ១៣

វណ្ណយុត្តិ-មេសូត្រ (ព្រហ្មគិត) .. ១៤

មុខងារនៃអក្សរ ... ១៨

ព្យាង្គរបស់ពាក្យ ... ១៩

ព្យាង្គតម្រួត ... ២០

សំឡេងអក្សរអឃោសៈ - ឃោសៈ .. ២១

នាមក្រិត - កិរិយាក្រិត ... ២២

នាម ... ២៥

លិង្គរបស់នាម ... ២៧

វចនៈ ... ២៨

គុណនាម ... ២៩

កិរិយាសព្ទ ឬ កិរិយា ..... ៣១

វិធីកាត់ពាក្យមានបន្តក់នឹងឥតបន្តក់ ៣៣

សព្វនាម ... ៣៤

កិរិយាវិសេសន៍ ... ៣៨

វិធីប្រើអាយតនិបាត ... ៣៩


## សារបាន


មាតិកា ទំព័រ

និបាតសព្ទ ... ៤៦

សំខ្យា ឬ សំខ្យាសព្ទ ... ៥២

បុព្វបទ ... ៥៤

អាគម - ឧបសគ្គៈ ... ៥៥

សម្ពន្ធ ... ៥៨

សមាសនាម ... ៧៥

ពាក្យកើតពីអក្សរ ឋ ន្ធ ថ ស្ន ស្ត ស្ថ ៧៨

ព្យញ្ជនៈផ្លាស់រូបតែសព្ទគង់នៅដដែល ៨០

អាខ្លាក់អាខ្វិននាំគ្នារត់ ... ៨២

សុភាទន្សាយ បានសង្គ្រោះត្រី .... ៨៤

វិជ្ជាសម្បត្តិ ... ៨៦

ទាងកន្ត្រី ... រិទ្ធិសែន ... ៨៧

សត្វទុងនិងត្រី ... ៨៩

ស្ត្រីពីរនាក់ដណ្តើមកូនគ្នា ... ៩០

រឿងខ្លាឃ្មុំនឹងដើមពង្រៃ ... ៩២

ឆ្មាស្រុកនិងចាបពួក ... ៩៤

ញោនឹងថ្នាក់រំពាក់នៅដៃ ... ៩៥

រឿងសត្វបង្កួយ ... ៩៧

អទ្ធបុព្វកៈ ... ៩៨

ស្តូបត្រី ... ១០០

ផ្លូវង ... ១០១

ផ្ញើហាប់ហោះ ៗ ចាប់វិញ ... ១០២

# សេចក្ដីផ្ដើម និង ការយល់ព្រម

ការកើតឡើងជាវិធីអក្ខរៈនេះ ដោយសារខ្ញុំយកចិត្តទុកដាក់ជាតិកំណើតរបស់ខ្ញុំជាទីស្រឡាញ់ ព្រោះការធ្វើនេះ គឺធ្វើដោយចិត្តឯង ពុំបានគិតកម្លាំងនឿយលំបាកឡើយ ។

វិធីអក្ខរៈនេះ រៀបតែនឹងបោះបង់ចោលអសារឥតការទៅហើយ ស្រាប់តែលោក អ៊ុម - ឈាងស៊ុន ទីប្រឹក្សាព្រះរាជ-អាណាចក្រ កាលលោកនៅជាចាងហ្វាងក្រសួងសិក្សាធិការក្រុងភ្នំពេញ លោកមានចិន្តារៀបចំវិជ្ជាខេមរភាសាឲ្យបានរៀបរយ ទើបលោកឲ្យខ្ញុំយកការដ៏តិចតួចនេះជូនទៅលោក ។

ក្បួននេះមានកំណើតជាដំបូងបំផុត របៀបវេយ្យាករណ៍ពុំបានជាប្រសើរណាស់ណាឡើយ តែខ្ញុំសូមដឹងគុណលោក អ៊ុម - ឈាងស៊ុន ជាទីបំផុតដោយសេចក្ដីដែលលោករាប់អានការតិចតួចរបស់ខ្ញុំមិនឲ្យសោះសូន្យ ។ លោកក៏បានចាត់ចែងឲ្យក្រុមវិទ្យាសាស្ត្រ ក្រសួងសិក្សាធិការ ពិនិត្យបោះពុម្ពផ្សាយតាមឃោសនាការ ពីឆ្នាំរកាស័ក ព.ស. ២៤៨៨ ម្ដងរួចហើយ ។

ដល់មកថ្ងៃទី១ ខែសីហា គ.ស. ១៩៥០ នេះ រោងពុម្ពខេមររដ្ឋ ក្រុងភ្នំពេញ បានទៅសុំសៀវភៅនេះអំពីខ្ញុំជាអ្នករៀបរៀង ដើម្បីនឹងយកទៅចាត់ចែងបោះពុម្ពទុកបម្រើដល់សិក្ខាកាមៈកុលបុត្រ ដែលស្រេកក្នុងការសិក្សាអក្សរសាស្ត្រខ្មែរ ជាវយកទៅសិក្សារៀនសូត្រឲ្យបានសម្រេចតាមបំណង ។

ខ្ញុំក៏បានយល់ព្រម អនុញ្ញាតឲ្យរោងពុម្ពខេមររដ្ឋបោះពុម្ពសៀវភៅនេះ តាមសេចក្ដីត្រូវការ ដោយសេចក្ដីសង្ឃឹមថា អក្សរសាស្ត្រខ្មែរ នឹងបានឡើងកាន់វឌ្ឍនធម៌ល្អគួរណាស់ដុះដាលលើសមុខ នឹងតទៅអនាគត ។

ព. ស. ២៤៩៣ គ. ស. ១៩៥០

ញូវ អ៊ុម

# វេយ្យាករណ៍ខ្មែរ

១ – វេយ្យាករណ៍ខ្មែរជាក្បួនបង្រៀនវិធីអក្ខរៈ ដើម្បីនិយាយត្រឹមត្រូវ សរសេរត្រឹមត្រូវក្នុងភាសាខ្មែរ ។ ក្បួនវេយ្យាករណ៍ប្រាប់ព្ធរៀបរៀងតាំងពីព្យញ្ជនៈ ។

អក្ខរៈ ឬអក្សរ ឬវណ្ណៈ មានពីរយ៉ាងគឺៈ ស្រៈ ឬសរៈ និងព្យញ្ជនៈ ។ ស្រៈមានពីរពួក ស្រៈពេញតួ និងស្រៈនិស្ស័យ ។

ស្រៈពេញតួមាន ១៥ គឺៈ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។

ស្រៈនិស្ស័យមាន ២០ តួគឺ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។

ព្យញ្ជនៈមាន ៣៣ តួគឺៈ ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ អ ។

ដែលហៅថាស្រៈពេញតួនោះ គឺស្រៈប្រើជាតួអក្សរៈដូចតួព្យញ្ជនៈដែរ ដូចពាក្យថា: អរគុណ អាប ឥឡូវ កៅអី ឧត្តម ឧស្សាហ៍ ឪឡឹក ឪឡោក ឫក្ស ឫស្ស ឫទ្ធិ ឮឬទេ? ឯក ឯនោះ ឰដ៏ ឰក ឲ្យ ឱដ្ឋ ឱស្ឋ អក អក់ អាចម៍ ក្រអៅ អាវ ឥត ។

ដែលហៅថាស្រៈនិស្ស័យនោះ ព្រោះអាស្រ័យនឹងតួព្យញ្ជនៈ



ទើបប្រើបាន ដូចពាក្យថា: កាម ដឹង ចុង កុដិ សូម លេង កាំបិត ប្រែង កន្តើយ ព្រះដើយ សម្បើម ទង់ពាញ ។

---

## ២ — ព្យញ្ជនៈ

ព្យញ្ជនៈតាំង ៣៣ ចែកជា ៥ វគ្គឬពួក នឹងសេសវគ្គ ១ ។ វគ្គនិមួយៗ មានអក្សរ ៥ តួ, ឯសេសវគ្គមានអក្សរ ៨ តួ ។ វគ្គទី ១ គឺ: ក ខ គ ឃ ង ។ វគ្គទី ២ គឺ: ច ឆ ជ ឈ ញ ។ វគ្គទី ៣ គឺ: ដ ឋ ឌ ឍ ណ ។ វគ្គទី ៤ គឺ: ត ថ ទ ធ ន ។ វគ្គទី ៥ គឺ: ប ផ ព ភ ម ។

សេសវគ្គគឺៈ យ រ ល វ ស ហ ឡ អំ ។

ព្យញ្ជនៈទាំងឡាយមានស័ព្ទសំឡេងជាពីរពួក ពួកសំឡេងតូចហៅថាអឃោសៈ ពួកសំឡេងធំហៅថាឃោសៈ ។

## អក្សរអឃោសៈ

ក ខ - ច ឆ - ដ ឋ - ត ថ - ប ផ - ស ហ - ឡ អ ។

## អក្សរឃោសៈ

គ ឃ ង - ជ ឈ ញ - ឌ ឍ ណ - ទ ធ ន - ព ភ ម - យ រ ល វ ។

អក្សរនៅចុងវគ្គទាំង៥ និងនៅចុងសេសវគ្គ ឈ្មោះនិគ្គហិតគឺ ង ញ ណ ន ម អំ ។ គួព្យញ្ជនៈទាំងឡាយមានសំឡេងប្លែកពីគ្នា: ខ្លះមានសំឡេងតែមួយ ខ្លះមានសំឡេងផ្សំ ។ គូដែលមានសំឡេងក្បតែមួយហៅថាសិថិល, គូដែលមានសំឡេងផ្សំហៅថាធនិត ។

## អក្សរសិថិល

ក គ - ច ជ - ដ ឌ - ត ទ - ប ព - យ រ ល វ ស ហ

និងនិគ្គហិតង ញ ណ ន ម អំ ។

## អក្សរផសិត

ខឃ - ឆឈ - ឋឍ - ថធ - ផភ ។

---

# ៣ — គូអក្សរ

ក្នុងវគ្គនិមួយ ៗ មានអក្សរជាគូគ្នាពីរគូ នោះគឺ:

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វគ្គទី | ១ | អក្សរ | ក | ជាគូនឹងអក្សរ | ខ | ៗ | គ | ជាគូនឹង | ឃ |
| „ | ២ | „ | ច | „ | ឆ | ៗ | ជ | „ | ឈ |
| „ | ៣ | „ | ដ | „ | ឋ | ៗ | ឌ | „ | ឍ |
| „ | ៤ | „ | ត | „ | ថ | ៗ | ទ | „ | ធ |
| „ | ៥ | „ | ប | „ | ផ | ៗ | ព | „ | ភ |

ឯអក្សរនៅសេសវគ្គជាតួសិថិលទាំងអស់ ឥតមានគូឡើយ នឹងអក្សរនៅខាងចុងវគ្គទាំង៥ ក៏ជាសិថិលឥតមានគូដូចគ្នាដែរ ។ អក្សរឥតគូ ឬអក្សរទោលទាំងនោះគឺ ង ញ ណ ន ម យ រ ល វ ស ហ ឡ ‑ំ ។

## ៨ — ព្យញ្ជនៈបន្ថែម

ដើម្បីនឹងប្រើការឲ្យគ្រប់គ្រាន់ក្នុងភាសា បុរាណការប្រើលោកបន្ថែមព្យញ្ជនៈដោយថែមវណ្ណយុត្តិមូសិកទន្ត នឹងត្រីសព្ទលើព្យញ្ជនៈខ្លះ ព្យញ្ជនៈទាំងនោះគឺ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊ ។ ព្យញ្ជនៈទាំងនេះពេលណាមានស្រៈនិស្ស័យ ិ ី ឹ ឺ ើ ភ្ជាប់លើក្ដី គេផ្លាស់វណ្ណយុត្តិ ៉ ៊ ជា ុ , ដូចពាក្យៈ បុិន មុឹន វុី បុី សុី ហុឹង អុី ។

---

## ៩ — វណ្ណយុត្តិ

សញ្ញាដែលបន្ថែមលើអក្សរៈ ដើម្បីនឹងសំរៀងសព្ទវែងជាសព្ទខ្លី ឬសំរៀងសព្ទឲ្យប្លែកពីសព្ទដើម ឬកាត់ពាក្យក្នុងប្រយោគជាសង្កាត់ដើម្បីឲ្យលះសេចក្ដីហៅថាវណ្ណយុត្តិ ។ វណ្ណយុត្តិទាំងឡាយគឺ បន្តក់ ( ់ ) មូសិកទន្ត ( ៉ ) ត្រីសព្ទ ( ៊ ) សំយោគសញ្ញា ( ៓ ) របាទ ( ៌ ) អស្ដា ( ៏ ) ទណ្ឌឃាត ( ៍ ) វិសជ្ជនីយ ( ះ ) កុក្កុដនេត្រ ( ៈ ) កាកបាទ ( + ) វង់ក្រចក ( ( ) ) អញ្ញត្តរ ( “..” ) លះ ( ។ល។ )

(មកពីពាក្យបេយ្យាលៈ គេយកតែអក្សរ ល ខាងចុង) គោមូត្រ ឬបរិយោសាន (៚—) ខណ្ឌ (។)

---

## ៦–វិធីប្រើវណ្ណយុត្តិ

បន្តក់ – សញ្ញានេះ សំរាប់ដាក់ថែមលើតួប្រកប ដែលព្យាង្គពាក្យកើតឡើងពីស្រៈអ និងស្រៈអា ហើយកាត់ស័ព្ទវែងជាស័ព្ទខ្លី ដូចពាក្យៈ ចង ស័ព្ទវែង, ចង់ ស័ព្ទខ្លី; ចាក ស័ព្ទវែង, ចាក់ ស័ព្ទខ្លី, ឃាត ស័ព្ទវែង, ឃាត់ ស័ព្ទខ្លី ... ឯអក្សរជាតួប្រកបរបស់ព្យាង្គពាក្យ ហើយទទួលសញ្ញាបន្តក់ (់) បានមានតែអក្សរទាំងនេះ ក ង ច ញ ត ន ប ម ល ស ។ អក្សរក្រៅពីនោះទៅ ទោះកាត់ស័ព្ទវែងជាខ្លីក៏ដោយ មិនដែលទទួលវណ្ណយុត្តិបន្តក់ (់) ឡើយ ដូចពាក្យៈ ជខ បថ សព្វ កត ... ប៉ុន្តែបើពាក្យណាដែលចេញមកពីបាលីឬសំស្រ្កឹត ទោះអក្សរដែលត្រូវទទួលបន្តក់ (់) បាន ក៏ពុំត្រូវដាក់បន្តក់ (់) ឡើយ ដូចពាក្យៈ កុសល ផល លាមច ធនធាន ជន សត្វ វត្ត ក្សត្រ ។





មូសិកទន្ត – សញ្ញានេះ សំរាប់ថែមលើអក្សរនៅដើមព្យាង្គពាក្យ កាលណាពាក្យនោះគ្មានព្យាង្គឯទៀតបន្ថែមមក ឬព្យាង្គនោះពោលគឺដាច់តែឯង ដូចពាក្យ ប៉ុន្តែ ប៉ុណ្ណឹង ម៉ត់ ញ៉ាំ ញ៉ី បើកាលណាមានស័ព្ទព្យាង្គដើម ឬតួអក្សរដើមបន្ថែមមក មិនត្រូវដាក់មូសិកទន្ត (") ឡើយ ដូចពាក្យ: ប្រមោយ ស្រវឹង បម្យា បម្រុង ប្រមាទ សង្កាត ក្នុង ខ្ញុំ ច្នុ គ្នាត .... ។

ត្រីស័ព្ទ – វិធីប្រើវណ្ណយុត្តត្រីស័ព្ទ មានលំនាំដូចគ្នានឹងមូសិកទន្តដែរ ដូចពាក្យ: ទ្រហឹង ត្រហា វិហារ ពហាន ។ ស៊ី ហ៊ឹងត្រចៀក អ៊ុត ហ៊ាន ស៊ុន ស៊ើបការ ... ។

សំយោគសញ្ញា – វណ្ណយុត្តិនេះ សំរៀងស័ព្ទបាលី ឬសំស្ក្រឹតមកជាស័ព្ទខ្មែរ ។ ឧបមាដូចពាក្យៈ (ភយ) ភ័យ; (ជយ) ជ័យ; (ខយ, ក្សយ) ខ័យ, ក្ស័យ; (ពន្ធ) ព័ន្ធ; (ពទ្ធ) ព័ទ្ធ; (យន្ត, យន្ត្រ) យ័ន្ត, យ័ន្ត្រ; យន្ត (យន់), (សម្បទ) សម្ប័ទ, សម្បត្តិ; (បច្ចយ); បច្ច័យ (អាលយ) អាល័យ; (សមយ) សម័យ; (សំសយ) សង្ស័យ; (ហទយ, ហឫទយ) ហទ័យ, ហឫទ័យ ។

សញ្ញានេះប្រើនូវពាក្យខ្មែរខ្លះដែរ កាលណាពាក្យនោះមិនពេញលេញ ជាពាក្យកើតមកពីស្រៈ អ ឬ អា ហើយអក្សរ រ ជាតួប្រកប ដូចពាក្យថាៈ ជ័រ ញ័រ ទំព័រ ចចីចច័រ ព្រឺព្រ័រ សាសន៍ព័រ ញញាក់ញញ័រ ... ។

របាទ – សញ្ញានេះជំនួស រ កាលណា រ ជាជំនួសតួអក្សរតម្រួត ។ របាទ (៌) ជាវណ្ណយុត្តិសំរាប់ដាក់ នូវពាក្យសំស្ក្រឹតក្លាយមកពីបាលី ។ ជាធម្មតា តួអក្សរណាដែលពុំសូវប្រើជាផ្ញើ ដើរជាគ្រាប់ តួតម្រួតអក្សរនោះផ្លាស់ជារបាទ ។ បើតួអក្សរណា

# វិធីប្រើវណ្ណយុត្តិ–៩



ធ្លាប់ប្រើ ក្រពាត់ក្នុងជើងជើង តួតម្រួតអក្សរនោះផ្លាស់ជាក្រពាត់ ។ តួតម្រួតផ្លាស់ជា រ ក៏បាន ដូចមានពាក្យតាំងនេះជាបែបយ៉ាង ៖

ណ្ណ = ណ៌, ម្ម = ម៌, ព្ព = ព៌, ព្ភ = ព៌, ពណ្ណ = ពណ៌, ធម្ម = ធម៌, គព្ភ = គភ៌, បុញ្ញ = បូញ៌, បរិបុណ្ណ = បរិបូណ៌ = បរិបូរណ៌ ។

មានអក្សរខ្លះដែលធ្លាប់មានជើងជើងក្រពាត់ ជាប់ដោយសញ្ញារបាទខ្លះ ក៏មានដែរ ដូចពាក្យៈ កក្កដ ជា កក៌ដ; វិសជ្ជនីយ ជា វិសជ៌នីយ, មគ្គុទ្ទេស ជា មគ្គុទេ៌ស, មគ្គ ជា មាគ៌, មារយាទ ជា មាយ៌ាទ ។

កំណត់កត់សំគាល់ - ក្ក = ក្រ, គ្គ = គ្រ, ទ្ទ = ទ្រ, ស្ស = ស្រ, ដូចពាក្យៈ បក្ក = បក្រ, វត្ត = វត្រ, បុត្ត = បុត្រ, សមុទ្ទ = សមុទ្រ... ប៉ុន្តែតួអក្សរដទៃពីរតួ ដូចពោលខាងលើនេះមិនផ្លាស់តួតម្រួតជា “រ” ឡើយ ។

អស្ដា – សញ្ញាអស្ដា ប្រើដាក់តែលើអក្សរ ក និង ដ ហើយ ក និង ដ នោះជាពាក្យនិបាត គឺពាក្យនោះមិនមែនជានាម ជាគុណនាមឬជាកិរិយាស័ព្ទ ដូចពាក្យថា: គេហាមដូចម្ដេច ក៏មិនស្ដាប់ ។ អ្នកបេះផ្កាដ៏ប្រសើរ រមែងរួចចាកពីអបាយភូមិ ។ ប្រសើរដ៏ឧត្ដម ។

ក្នុងពាក្យឧទានស័ព្ទ គឺពាក្យថាដោយភ្ញាក់ផ្អើល សញ្ញានេះ មានប្រើខ្លះដែរ ដូចពាក្យ: ឱហ្ន៏ ! ឱន៏ ! ទុ៎ះហ្ន៏ ប្អូន៏ ! ។

ទណ្ឌឃាត – ទីនឹងបដិសេធតួអក្សរលើសពីការ គេដាក់ទណ្ឌឃាត: រ័តន៍, គោទក៍, ពេទ៍, ប្រយោជន៍... ។

វិសជ្ជនីយ – សញ្ញានេះប្រើជំនួសខ្យល់ "ស" ស័ព្ទខ្មែរ: នេះ, ព្រោះ, ដះ.... ។

កុក្កុដនេត្រ – សញ្ញានេះ សម្រាប់ប្រើផ្ដើមសេចក្ដី ។

កាកបាទ – សម្រាប់ប្រើពាក្យឧទានសព្ទ និងពាក្យវិសេសនបព្វនាមខ្លះ ដូចពាក្យថា: ប៎ះ ! ហ៎ា ! នុ៎ះ ។

វង់ក្រចក — សញ្ញាវង់ក្រចកសំរាប់ដាក់គៀបពាក្យណា ឬ ឃ្លាណាមួយ ដែលមិនមានទាក់ទងនឹងបូលក្តីអត្ថបទនោះទេ គ្រាន់តែជាសំគាល់ពន្យល់ពាក្យណាមួយ ដែលមានក្នុងអត្ថបទនោះៗ ដូចពាក្យថា: បិតាខ្ញុំអញ្ជើញទៅប្រទេសថៃឡង់ដ៍ (ប្រទេសសៀម) តាំងពីខែមេសាម្ល៉េះ ។

អត្តន្តរៈ — សញ្ញាអត្តន្តរៈ សំរាប់ដាក់គៀបឃ្លាណា ដែលមានសារប្រយោជន៍ច្រើន ឬ ឃ្លាណាដែលអ្នកនិពន្ធចង់ឲ្យអ្នកអានយកចិត្តទុកដាក់ប្រុងអានឃ្លានោះជាពិសេស ដូចពាក្យថា ខ្មែរជនយើងដឹងគ្រប់គ្នាថា "ចេះពីរៀន មានពីរក" ប៉ុន្តែមិនមានជនណាមួយ ចំអនុវត្តតាមពាក្យចំនៀមនោះសោះ ។

ល:ៗ ល:ៗ — សញ្ញាល: (ៗល:ៗ) នេះ សំរាប់ប្រាប់ថាពាក្យដែលគេរាប់រៀបនោះ មិនទាន់អស់ទេនៅមានតទៅទៀត ។

គោមូត្រ ឬ បរិយោសាន — សញ្ញានេះ សំរាប់បញ្ចប់សេចក្តីជាស្រេចឥតមានតទៅទៀត ។

ខណ្ឌ - សញ្ញាខណ្ឌនេះ សំរាប់ដាក់សេចក្ដីសង្កាត់ៗ ដើម្បីធ្វើសេចក្ដីនោះឲ្យល្អស្ដាប់ ។

---

## ៧ - អក្សរព្យញ្ជនៈផ្លាស់ប្ដូររូប

គួអក្សរផ្លាស់ប្ដូររូប កើតឡើងអំពីពាក្យបាលី ដែលក្លាយទៅជាពាក្យសំស្ក្រឹត ពាក្យទាំងនោះខ្មែរប្រើទាំងបាលីទាំងសំស្ក្រឹត ៗ ន័យរបស់ពាក្យដូចគ្នា ៗ ស័ព្ទនិងរូបអក្សរដូចគ្នា ៗ គួផ្លាស់ប្ដូររូបទាំងឡាយនោះ ទឹងសំរេចជាក្បួនដាច់ស្រេចពុំបាន មានគួរៈផ្លាស់ៗសរបៀបក៏មាន ប៉ុន្តែការផ្លាស់គួជាញឹកញយនោះ ដូចមានពាក្យឧបមាទាំងនេះ អក្ខរៈផ្លាស់ជាអក្សរ, យក្ខៈ ជាយក្ស, រុក្ខៈ ជាព្រឹក្ស, សិក្ខា ជាសិក្សា, ខត្តៈ ជាក្សត្រ, ខេត្តៈ ជាក្សេត្រ, ខេមៈ ជាក្សេម, ខណៈ ជាក្សណៈ, ខីរៈ ជាក្សីរ, និច្ចៈ ជានិត្យ, កិច្ចៈ ជាក្រឹត្យ, អាទិច្ចៈ ជាអាទិត្យ, វិនិច្ឆ័យ ជាពិនិស្ច័យ, អច្ឆរិយៈ ជាអស្ចារ្យ, បច្ឆិមៈ ជាបស្ចិម, វិជ្ជា ជាវិទ្យា, វេជ្ជៈ ជាពេទ្យ, សម្ពោជ្ឈៈ ជាសម្ពោធ្យ សម្ភោធ្យ, មជ្ឈិមៈ ជាមធ្យម, ឈានៈ ជាធ្យាន, វេជ្ឈៈ

ជាសេស្ឋ, អធិដ្ឋានៈ ជាអធិស្ឋាន, ព្រះឱដ្ឋៈ ជាព្រះឱស្ឋ ឋិតៈ ជា ស្ថិត, ឋានៈ ជា ស្ថាន, ថនៈ ជា ស្តន, ព្រះហត្ថៈ ជា ព្រះហស្ត, វត្ថៈ ជាវស្ត្រ ។ អត្ថៈ ជាអាថ៌... ចក្កៈ ជា ចក្រ, បុត្តៈ ជាបុត្រ, រត្តិ ជារាត្រី, មេត្តា ជា មេត្រី ។ សមុទ្ទៈ ជា សមុទ្រ, កទ្ទមៈ ជា កទ្រម, វេស្សវណៈ ជា វេស្រវណ, ធម្មៈ ជា ធម៌, មគ្គៈ ជា មាគ៌, បុព្វៈ ជា បូព៌, បរិបុណ្ណៈ ជា បរិបូណ៌ ឬ បរិបូរណ៍, បុណ្ណមី ជា បូណ៌មី, គព្ភៈ ជា គភ៌, ទុគ្គតៈ ជា ទុគ៌ត ឬ ទុរគត ។

## ៨- វិធីស្វាធ្យាយន៍បាំមាត់

ក្ខ ផ្លាស់ជា ក្ស, ច្ឆ ផ្លាស់ជា ក្ស, ច្ឆ ផ្លាស់ជា ស្ច; ជ្ឈ ផ្លាស់ជា ទ្យ, ជ្ឈ ផ្លាស់ជា ធ្យ, ដ្ឋ ផ្លាស់ជា ស្ឋ; ថ ផ្លាស់ជា ស្ថ ។ ក្ក កម្រូតជា ក្រ, ត្ត កម្រូតជា ត្រ, ទ្ទ កម្រូតជា ទ្រ ។ ម្ម កម្រូជា ម៌, ណ្ណ កម្រូតជា ណ៌, ព្វ កម្រូតជា ព៌, គ្គ កម្រូតជា គ៌, ទ្ទ កម្រូតជា ទ៌, ក្ក កម្រូតជា ក៌ ។

មានពាក្យខ្លះកើតពីអក្សរ វ ទីង ព ផ្លាប់បត្គា ដូចពាក្យ ឋាៈ វាទ វាចា ជា វាក្យ ឬ ពាក្យ, វេលា វិលា ជាពេល,

វនៈ ជាពន (ព្រៃ), វរៈ ជា ព្រះ, វ្ឫក្សៈ ជាព្រឹក្ស, វំសៈ ជា វង្ស ឬ ពង្ស, វិសាខៈ ជា ពិសាខ, វ្ឫហស្បតិ ជា ព្រហស្បតិ៍, ទិក្ខណៈ ជា ទិក្ខាន, ហេមវន្តៈ ជាហេមពន្ត... ។

ពាក្យខ្លះទៀតដូចៈ សត្តៈ ជាសត្វ, សតវស្ស ជា សតវត្ស ឬ វត្សរ៍, បៀវស្សៈ ជា បៀវត្ស... ។

---

## ៩ – វណ្ណយុត្តិ – មេសូត្រ (ព្រហ្មគីត)

អ្នកអើយវិសញ្ញា ត្រូវសិក្សាចេះឲ្យមុត
ឲ្យស្គាល់គ្រឿងវណ្ណយុត្តិ ប្រុងស្វាហ៍គិតរំពឹង ។

( ់ បន្តក់ )

សញ្ញាមួយនោះណា រាងរូបាទ្រង់ដូចស្នឹង
បន្តក់វណ្ណយុត្តិហ្នឹង កាត់ស័ព្ទវែងជាស័ព្ទខ្លី ។

( ៉ មូសិកាទន្ត )

ស្នឹងពីរដាក់ទឹមគ្នា លើអក្ខរាប្រែសំដី
ឈ្មោះមូសិកទន្តី ធ្មេញកណ្ដុរចូរចាំទុក ។

( ័ សំយោគសញ្ញា )

វណ្ណយុត្តិមួយនោះនៃ　　រាងខ្បមេឃ្យដូចជាកុក
តដសារ "ង" នៅមុខ　　ហៅថាសំយោគសញ្ញា ។

( ៌ រេផៈ )

រេផជាវណ្ណយុត្តិ
តួសន្មតជំនួស "រ"
ទ្រង់ត្រាយក្រង់ "ង"
ដូចលំនាំកក្រសារ ។



( ៏ អស្តា )

សញ្ញាមួយវិញនោះ　　អស្តាស្មោះកងគាយា
អ្នកប្រាជ្ញបញ្ញត្តថា　　ឲ្យប្រើលើ "ជ" និង "ក" ។

( ់ ទណ្ឌឃាត )

ទណ្ឌឃាតសម្រាប់បង់　　តួមួយអង្គនៃអក្ខរ
ដែលលើសពីសំតួថា　　តាមគម្រាគេតគពោល ។

# ១៦ – ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

( ៈ វិសជ្ជនីយ )

វិសជ្ជនីយសញ្ញានោះរុញសូរជាអះ ដូចប្រើពាក្យ "តោះ" "រួះ" "មោះ" "សោះ" "បោះ" សឹងក្បៀសពីរ ។

( ៙ កុក្កុដនេត្រ )

សញ្ញាវង់ភ្នែកមាន់ ចូរកុំភាន់ក្នុងដួងថៃ
អ្នកប្រាជ្ញលោកកែវ ទុកជាដើមផ្ដើមសេចក្ដី ។

( + កាកបាទ )

កាកបាទរៀវជើងក្អែក ជាចំណែកសញ្ញាគោល
បិតលើពាក្យពាំនោល ដូចជា ចា៎ះ នុ៎ះ ណា៎នែ ។

( () វង់ក្រចក )

ពាក្យខ្វះគួរបដិសេធ តែដោយហេតុលុបមិនបាន
ហ្នោះហើយទុកឲ្យមាន ដាក់នៅក្នុងវង់ក្រចក ។

( « ... » អត្ថត្ថរៈ )

សញ្ញាជាក្រោយនេះ នាមជាអត្ថទ្វី
ប្រត្យ័ក្សពាក្យក្នុងនី ដែលត្រូវឃើញយល់ជាក់ស្ដែង ។

( ៗលៗ លះ )

មាតិកាសំដែងវែង    គេចាំបែងទុកលៃលក
ដាក់ប្រមពាក្យនោះមក    តំណាងជាសញ្ញាលះ ៗ

( ៙— បរិយោសាន )

បរិយោសានសោត    ម្ដគោមូត្រចប់សំដី
សំដែងរឿងអ្វី    ចូរឃើញដឹងដោយងាយពេក ៗ

( ៗ ១ណ្ណា )

វិ១ណ្ណសញ្ញាកាត់    ជាសង្កាត់តាកស្នាក់ស្មើរ
ឲ្យសេចក្ដីប្រសើរ    ឯរូបភាពដូចឈើត្រាន ៗ

( – យុតិភង្គ )

សញ្ញាជាបណ្ដាច់    ក្រោយសំរេចមួយនេះឯង
ភ្ជាប់បាទកាព្យចាំបែន    ដែលព្យាង្គបែកចេញពីគ្នា ៗ
រីឈ្មោះសញ្ញានេះ    ចូរចាំចុះកុំកង្វា
យតិភង្គនាមា    ដកាបនៅកុំបំភ្លាយ ៗ

## ១០-- មុខងារនៃអក្សរ

ពាក្យដែលយើងនិយាយមួយម៉ាត់ៗ ពោះពាក្យមានតួអក្សរប្រកបក្តី ពាក្យគ្មានតួអក្សរប្រកបក្តី ហៅថាព្យាង្គ ព្យាង្គដែលមានអក្សរជាតួប្រកបសម្រាប់ព្យាង្គនោះ គឺជានឹងផ្លាស់ប្តូរតួប្រកបពុំបានឡើយ ។ ឧបមាដូចពាក្យ: មុខ-មគ្គ-សព្ទ សុខ-ជ្រាប-ទើប...: នឹងសរសេរ: មុក-មាក់-សប់-សុក-ជ្រាព-ទើព... ដូច្នេះវិញពុំបានឡើយ ។ ភាសាខ្មែរប្រជុំនៃភាសា ៣ គឺ: ភាសាអ្នកស្រុក, ភាសាបាលី នឹងភាសាសំស្ក្រឹត ។ វេយ្យាករណ៍ចែកមុខងារអក្សរព្យញ្ជនៈដាច់ស្រឡះ នោះអក្សរជាតួប្រកបនូវពាក្យខ្មែរ សឹងជាអក្សរនៅដើមវគ្គគឺ: ក ច ដ ត ប ។ អក្សរប្រកបនូវពាក្យបាលីដែលប្រើក្នុងភាសាខ្មែរ ឬពាក្យសំស្ក្រឹតក្តី សឹងជាអក្សរទី ២ ទី ៣ ទី ៤ ក្នុងវគ្គគឺ: ខគឃ ឆជឈ ឋឌឍ ថទធ ផពភ ។ ឯអក្សរនៅចុងវគ្គ នឹងអក្សរនៅសេសវគ្គគឺ: ងញណនម យរលវ សហឡ ប្រើបានជាតួប្រកបនូវពាក្យខ្មែរ

ពាក្យបាលីនឹងពាក្យសំស្ក្រឹតជាមួយគ្នា ។ ន័យមួយវិញទៀត អក្សរទាំងឡាយដែលចាត់ជាតួប្រកបនូវពាក្យមកពីបាលីឬសំស្ក្រឹត អក្សរទាំងនោះមិនត្រូវមានសញ្ញាបន្តក់ថែមពីលើឡើយ ។ ព្រោះពាក្យនោះមានសព្ទវ៉ក៏ដោយ ដូចពាក្យ: សព សត្វ ផល កុសល ជន ធនធាន ពល ប្រាកដ សន្ទត លាមក ជាដើម ។

---

## ១១ — ព្យាង្គរបស់ពាក្យ

តួអក្សរផ្សំគ្នា ឬតួនឹងស្រៈផ្សំគ្នា កើតឡើងជាពាក្យ ពាក្យទាំងនោះ ពាក្យខ្លះមានព្យាង្គតែមួយ ពាក្យខ្លះមានព្យាង្គ ២ ឬហៅពាក្យពីរព្យាង្គ ពាក្យខ្លះបីព្យាង្គ ពាក្យខ្លះមានព្យាង្គច្រើនទៀត ។ ព្យាង្គគោលឬពាក្យព្យាង្គតែមួយ: ចាស់ - នៅ - ទឹក - ថ្ងៃ - លេង ។ ពាក្យពីរព្យាង្គ: លំនៅ - បំណាច - បន្ទា - សណ្ដែក ... ។ ពាក្យបីព្យាង្គ: បម្បាជក់ - បន្ទាទូក - កន្ដេះឡង់ ... ។ ពាក្យច្រើនព្យាង្គ: អម្ពិលអំពែក - ទោសានុទោស - ថេពនុគេរៈ - រាជកិច្ចានុកិច្ច ។

---

## ១២ - ព្យាង្គតម្រួត

ពាក្យទាំងឡាយមានពាក្យខ្លះកើតឡើងពីព្យាង្គកាយ ខ្លះពីព្យាង្គតម្រួត ៗ ព្យាង្គតម្រួតកើតពីពាក្យពីរព្យាង្គជាធម្មតា, កាលណាព្យាង្គទាំងពីរនោះ ព្យាង្គខាងដើមមានអក្សរប្រកប ហើយអក្សរប្រកបនោះ ជាអក្សរនៅក្នុងវគ្គជាមួយគ្នា នឹងពាក្យព្យាង្គបន្ទាប់ ហើយព្យាង្គទាំងពីរ បើញែកគ្នាចេញព្យាង្គមួយ ៗ គ្មានស័ព្ទប្រែ បើប្រែបានក៏ប្រែខុសសំដៅដូចពាក្យថា: សន្ទូច, បណ្ដើរ .. បើញែកថា សន់-ទូច, បន់-ដើរ នោះពាក្យនិមួយ ៗ គតស័ព្ទថាជាអ្វី ៗ នឹងតម្រួតពាក្យលុះតែអក្សរប្រកបរបស់ព្យាង្គដើម នឹងអក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់ផង គឺជាអក្សរទី ១ នៅលើទី ២, អក្សរទី ៣

នៅលើទី៤, អក្សរទី៥ នៅលើអក្សរទាំង៤ ខាងដើមនៃវគ្គ ដូចពាក្យ ភិក្ខុ - ព្យគ្ឃ (ខ្លា) - អង្គរ - សង្ខារ - បង្គាប់ - សង្ឃឹម - ចិញ្ចឹម - បញ្ឆិម មជ្ឈិម - ដណ្ដើម - កណ្ដូប - កន្ដាំង... ។



ឯអក្សរក្នុងពួកសេសវគ្គគឺ: យរលវ សហឡអ បើត្រូវពាក្យត្រួតនោះទឹងនៅក្រោមតួណាៗបាន ដូចពាក្យ: អង្វរ - ពន្យល់ - បន្ទ្រាត់ - បទ្មា - ព្រឹង - បណ្ហា - បញ្ហា... ។

## ១៣ - សម្លេងអក្សរ អឃោសៈ - ឃោសៈ

អក្សរដែលមានសម្លេងតឹងហៅថា អឃោសៈ អក្សរដែលមានសម្លេងធូរ ឬបំភ្លេងធំហៅថា ឃោសៈ ។ សញ្ញាដែលសំគប់បន្ថែមលើតួព្យញ្ជនៈ ង ញ ប ម យ រ ល វ ស ហ ឡ អ ដើម្បីប្រើឲ្យគ្រប់គ្រាន់ក្នុងការ នោះកាលណាព្យាង្គពីរ ហើយព្យាង្គដើមមានស័ព្ទជាអឃោសៈ ឬជាឃោសៈ ព្យាង្គខាងចុងក៏នៃសម្លេងទៅ

តាមព្យាង្គដើមមិនបាច់ថែមវណ្ណយុត្តិឡើយ ដូចពាក្យៈ សង្កាត-សម្-ប្រមាទ - សមា - ចម្បា - សាលា - កុមារ - ប្រវែង ចម្ងាយ - សន្យា - សន្ទក - សញ្ញា - ប្រាជ្ញា - វិហារ - ពាហាន - ដំហាន - ដំហារ ... ។

គូព្យញ្ជនៈផ្សំដែលហៅថាផ្ញើជើងនោះ ជើងអក្សរដែលយកទៅផ្សំ នៃសម្លេងទៅតាមគូលើ តាមដោយសំពួកសម្លេងជា ឃោសៈ ឬ ជាអឃោសៈ មិនបាច់មានវណ្ណយុត្តិដូចគ្នា ។ ចូរមើលព្យញ្ជនៈផ្សំទាំងនេះ៖ ក្ល គ្ល ខ្ល ឃ្ល ក្ន គ្ន ខ្ន ឃ្ន ឈ្ន ថ្វ ធ្វ ថ្វ ធ្វ ខ្វ ខ្វ ខ្ម ខ្ម ស្ន ស្ម ក្រ គ្រ ច្រ ប្រ ស្រ គ្រ ទ្រ ព្រ ម្រ ... ក្នុង, កើតឃ្លង់, គ្នីគ្នា ... ។

---

## ១៤ — នាមក្រិត - កិរិយាក្រិត

អក្សរជាគូទឹងគ្នាក្នុងវគ្គ - ពាក្យយារចេញពីពាក្យដើម ឬបែកចេញពីពាក្យដើមហៅថាកិតៈ ឬក្រិត ។ ដៅនៃពាក្យទាំងឡាយ សឹងបែកចេញទៅពីគូឯង ឬចេញទៅពីអក្សរជាគូដូចពាក្យៈ ឈ្នួញ បែកចេញទៅជាពាក្យ ចំណួញ, កោស ចេញ





ទៅជាខ្នោស, គាបទៅជាឃ្នាប, ឆីទៅជាចំណី, ឆ្អិន ទៅជាចំអិន, ធ្ងន់ ទៅជាទម្ងន់, បួស ទៅជាផ្នួស, ពំនូន ទៅជាកន្ធូន, គិត ទៅជាគំនិត, កាត់ ទៅជាកំណាត់, ទើបទៅជាទំនើប..។

លើកតែពាក្យខ្លះ ដែលវេយ្យាករណ៍ មានអធ្យាស្រ័យឲ្យប្រើដូចពាក្យៈ ដើរ ទៅជាថ្មើរ, ត្រង់ទៅជាដម្រង់ ឬតម្រង់, ត្រូវ ទៅជាតម្រូវ ឬដម្រូវ, ប្រជុំ ទៅជាក្ជុំ... កិរិយាដែលបែកទៅជានាម ហៅថាកិរិយាក្រិត ។ នាមដែលចេញមកពីកិរិយា ហៅថានាមក្រិតឬហៅថាកិតនាមក៏បាន ។ កិតនាមខ្លះជាកិរិយា ផងជានាម

## ២៤- អ្នក មជ្ឈិមដ្ឋាន នឹង ឧត្តមដ្ឋាន





ដូចពាក្យៈ អ្នកដើរ អ្នករែក អ្នកដេក អ្នកមក អ្នកបេះ អ្នកទៅ សឹងជាកត្តិកនាម ។

ជំនុំនៃពាក្យ- ពាក្យដែលយើងនិយាយ កើតឡើងពីស័ព្ទច្រើនយ៉ាង:

១- នាម ។ ២- គុណនាម ។ ៣- កិរិយា ។ ៤- សព្វនាម ។ ៥- កិរិយាវិសេសន៍ ។ ៦- និបាត ។ ៧- ឧទានស័ព្ទ ។ ៨- បរិវារស័ព្ទ ។

## ១៥ - នាម

ករំដីដែល សំដែងនូវឈ្មោះ ជាគ្រឿងសំគាល់ឲ្យហៅបាន ដូចពាក្យថា: មនុស្ស-សត្វ-ដី-ទឹក-ខ្យល់-ឈើ-ទន្លេ-សមុទ្រ ៘ ពាក្យទាំងឡាយនោះហៅថានាម ។ នាមនាម មានពីរយ៉ាងគឺ: សាធារណនាម ១ អសាធារណនាម ១ ។

### សាធារណនាម

វត្ថុទាំងឡាយ ដែលមានបែបសណ្ឋានណាំគ្នាប្រហែលគ្នា ជាសាធារណនាម ដូចពាក្យហៅថា "ផ្ទះ" វត្ថុឯណាដែលមានភាព បែបប្រហែលនឹង



# ២៦ – ឋាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

គេហស្ថាននោះហៅថាផ្ទះដូចគ្នា ។ "ស្រែ" វត្ថុណាមានភាពដូចដី



នោះហៅថាស្រែដូចគ្នា ។ "ឆ្កែ" សត្វឯណា មានភាពដូចគ្នាហៅថាឆ្កែ ។ "ដើងតាំង" វត្ថុមានភាពដូចដើងមាំនោះ ហៅថាដើងតាំង.. ។

ពាក្យហៅថា ផ្ទះ-ស្រែ-ឆ្កែ-ដើងតាំង ជាសាធារណនាម ។

## អសាធារណនាម

នាមអ្វីសំរាប់តែមនុស្សម្នាក់ សត្វមួយ ឬវត្ថុមួយផ្សេងម្នាក់ឯង ហៅថាអសាធារណនាមព្រោះនាមនោះមិនចំពោះទូទៅឡើយ ដូចនាមថា: ភ្នំពេញ - មេកុង - ក្រចេះ - ស៊ីសុវត្ថិ - នរោត្តម . . . ឈ្មោះភ្នំពេញសំរាប់តែក្រុងខ្មែរម្នាក់ឯង, ឈ្មោះមេកុងសំរាប់តែទន្លេ នៅស្រុកខ្មែរនេះ, ឈ្មោះស៊ីសុវត្ថិ-នរោត្តម សំរាប់តែរូបស្តេចដែលសុគតហើយនោះ ។

# ១៦-លិង្គរបស់នាម

តាមនាមទាំងឡាយមានភេទផ្សេងគ្នា ភេទរបស់នាមនោះហៅថាលិង្គ ។ លិង្គមាន ៣ យ៉ាងគឺ: បុំលិង្គ (បុំងលឹង), ឥត្ថីលិង្គ, នបុំសកលិង្គ ។ បុំលិង្គគឺភេទសំរាប់មនុស្សប្រុស សត្វឬវត្ថុឈ្មោល, ឥត្ថីលិង្គ គឺភេទសំរាប់សំគាល់មនុស្សស្រី សត្វឬវត្ថុញី, នបុំសកលិង្គជាភេទសំគាល់មនុស្ស សត្វឬវត្ថុខ្ទើយ គឺភេទមិនមែនជាប្រុសឬជាស្រី ជាឈ្មោលឬញី ។ តាមដោយបញ្ញត្តិនៃក្បួនហោរា នាមរស់មនុស្សប្រុស អក្សរបស់មន្ត្រីសឹងជាបុំលិង្គ ។ នាមរបស់មនុស្សស្រី នាមរបស់ស្រុក-ភូមិ-នគរ-វត្ត-ខេត្ត-សឹងជាឥត្ថីលិង្គ ។ នាមរបស់មនុស្សខ្ទើយជានបុំសកលិង្គ ។ ឯក្នុងល្បែងខ្លះ វត្ថុដែលជាគ្រឿងលេងសឹងជាឥត្ថីលិង្គ ដូចអង្គញ់-មេប្រុក... ។

លិង្គប្រើជាពាក្យសំរាប់ប្រុសស្រី ដូចពាក្យថា: មា-ធុ-តា-ពូ-ធំ-អយ្យកោ-បិតុលា-កុមារ-យក្ស-យក្ខ-ចោរ-ភទី-ភទិទ-ភិក្ខុ-សាមណេរ-គោ-ពានរ..., ជាពាក្យសំរាប់បុំលិង្គ ។ ដូចពាក្យ

ហៅថា មីង - ម៉ែ - យាយ - អយ្យិកា - មាតុច្ឆា - កុមារី - យក្សិណី, (យក្ខិន) - ទេវី - ភគិនី - ភិក្ខុនី - ភិក្សុណី - សាមណេរី - នារី - ពានរី ព្រាហ្មណី... ជាពាក្យសំរាប់ឥត្ថីលិង្គ ។

## ១៧ វចនៈ

វចនៈ ជាពាក្យសំគាល់វត្ថុតែមួយ ឬវត្ថុច្រើន ។ ពាក្យដែលតំណាងវត្ថុតែមួយហៅថាវចនៈ ។ ពាក្យដែលតំណាងរបស់



ច្រើនហៅថាពហុវចនៈ ។ ក្នុងវចនៈទាំងពីរ យ៉ាងមិនជាការសំខាន់ពេកឡើយ, កាលណាគេចង់ប្រើជាពហុវចនៈ គេផ្ទួនពាក្យ ឬ តថែមពាក្យទៀតដូចជា: ប្រុស ៗ ស្រី ៗ ក្មេង ៗ កូនទាំងឡាយ ឈើទាំងឡាយ អស់ទាំងសត្វ ។ តែមានពាក្យខ្លះដែលចេញពីបាលី ឬ សំស្រ្កឹត មានសំគាល់វចនៈខ្លះដែរ ដូចពាក្យថា: រុក្ខ - រុក្ខា, យក្ស - យក្សា . . . រុក្ខ (ឯកវចនៈ), រុក្ខា (ពហុវចនៈ), យក្ស (ឯក) យក្សា (ពហុ.) ។

# ១៨ – គុណនាម

ពាក្យដែលសំដែងលក្ខណៈរបស់នាម ឬធ្វើនាមឲ្យមានបទ ដូចពាក្យថា: ថ្មរឹង-មនុស្សចាស់-ដែកស្និត-កែវស្រួយ... រឹង ចាស់ស្និតស្រួយ ប្រាប់លក្ខណៈ ថ្ម-មនុស្ស-ដែក-កែវហៅថា គុណនាម ។ នាមនាមមានលក្ខណៈសម្រេចហើយហៅថា



គុណបទ ។ គុណនាមមានបីយ៉ាងគឺ: បកតិគុណនាម ១, វិសេសគុណនាម ១, អតិវិសេសគុណនាម ១ ។

## បកតិគុណនាម

គុណនាមសំដែងលក្ខណៈតាមលំអានជាប្រក្រតី ដូចពាក្យថា: ភ្នំធំ - ទន្លេវែង - ស្លឹកស្តើង - វង់មូល - ដីខ្ពស់ - សេះធាត់ - សំពត់ម៉ដ្ឋ ស្រមោចតូច - អាវខ្លី - ក្តារក្រាស់ - ប្រាក់រៀលសំប៉ែត - ក្មេងទាប គោស្គម - មនុស្សកំសោយ - ជាងប្រសប់ - កប៉ាល់លឿន - សក់ស្កូវ ·

# ៣០ – ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

ផ្ទះធំ - ខ្ទះស្រែកាល - ព្រានបោត - ភ្លើងក្ដៅ - ទឹកត្រជាក់ - ខ្យល់រងា-

ត្បូងភ្លឺ - គុរលោន ឆ្កែកាច . . . ៗ

## វិសេសគុណនាម



គុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យវិសេសឡើង ដូចពាក្យថា: ផ្លូវត្រង់ជាង - ឆ្កែនេះកាចជាង - គោនេះធំជាង - មនុស្សប្រសប់ជាង - កាំបិតមុតជាង - ឈើខ្ពស់បែក . . ៗ

## អតិវិសេសគុណនាម

គុណនាមដែលសំដែងលក្ខណៈឲ្យវិសេសបំផុត ដូចពាក្យថា: ប័ណ្ណសផង - កំពោរសក្បូស - ស្បែកខ្មៅបង់ - កាំបិតមុតណាស់- គោយឺតណាស់ - កូនឧស្សាហ៍ណាស់ . . . ៗ

# ១៩ - កិរិយាស័ព្ទ ឬកិរិយា

ពាក្យពោលទូទៅអំពើធ្វើ ឬពោលទូទៅដំណើរជាអ្វី ហៅថា កិរិយាស័ព្ទ ដូចពាក្យថា: ដើរ - ឈរ - អង្គុយ - ដេក - ស៊ី - ផឹក - ងូត - លាង - និយាយ - ស្តី - ហៅ - យំ - ស្រែក - រាយ - ដំ - ដឹក - គាស់ - ឈូស - ចាំង - ភ្ជួរ - រាស់ - កាប់ - កាត់ - អាន - សរសេរ - តែង - ធ្វើ ... ។



ពាក្យជាកិរិយាស័ព្ទ មានប្រធានកាលណាគេចងជាប្រយោគដូចពាក្យថា: ខ្ញុំដើរ... ខ្ញុំជាប្រធានរបស់កិរិយាដើរ ។ យើងដេក - គេឈូស - វាធ្វើ - កូនសិស្សសរសេរ - អ្នកស្រែភ្ជួរ... ។ កិរិយាមានពីរយ៉ាង គឺ: សកម្មកិរិយា ១, អកម្មកិរិយា ១ ។

## សកម្មកិរិយា

គេហៅថាកម្មគឺពាក្យដែលប្រើសំរាប់បំពេញអំពើរបស់កិរិយា គេហៅថាសកម្មកិរិយា គឺកិរិយាដែលត្រូវមានពាក្យមកបំពេញអំពើទើប

# ៣២ - ញាក់ ផ្សៀមបង្ហាត់ និង ខ្លួមបង្ហាត់



គ្រប់គ្រាន់ដូចពាក្យថា: ខ្ញុំឈូសឈើ, គេទិញសំពត់, អ្នកទេសាចស្ទួចត្រី, ចោរលួចទ្រព្យ... ។ ឈើ-សំពត់-ត្រី-ទ្រព្យ ជាកម្មរបស់កិរិយា ឈូស-ទិញ-ស្ទួច-លួច ។

## អកម្មកិរិយា

កិរិយាដែលមានអំពើគ្រប់គ្រាន់នឹងខ្លួនឯងហើយ ហៅថា អកម្មកិរិយា ដូចពាក្យថា: ខ្ញុំកើត, យើងទៅ, វាស្លាប់, កប៉ាល់ចេញ, ក្មួយខ្ញុំមក, ប្អូនខ្ញុំដល់, ឈឺងាប់, សត្វហើរ, គេឈរ, ទឹកហូរ, គោបោល,



ផ្កាល្អ, គោរោទ៍, ព្រាបថ្ងូរ, ខ្លាគ្រហឹម, សំពត់ជ្រុះ, លោកមានប្រសាសន៍ ... ។

កិរិយាមានឈ្មោះហៅថា ហេតុកិរិយា គឺកិរិយាដែលធ្វើអំពើទៅគេ ដូចពាក្យថា: បង្រៀន គឺធ្វើអំពើទៅគេ ។

កិរិយាហៅថាសុទ្ធកិរិយា គឺកិរិយាដែលធ្វើចំពោះខ្លួនឯង ដូច ពាក្យថា: រៀន គឺធ្វើអំពើចំពោះខ្លួនឯង ។

## ២០-វិធីហាត់

ពាក្យមានបន្តក់ – កង់ កត់ កប់ ខ្លី់ ទល់ សក់ យល់ ពន់ ទក់ ធន់ បត់ បង់ បង់ ហាត់ ព្រនង់ កំពង់ ពន្យល់ ទំនប់ កញ្ចក់ បង្កង់ ដំទង់ គំរប់ ទំរង់ ចំណង់ កង្វល់ បង្អស់ បន្តក់ បំរត់ បន្ទប់ សំណល់ កញ្ជក់ កាត់ ខាត់ សាត់ ចាត់ ផាត់ ភ៉ត់ ហាត់ អាត់ ណាត់ បង្ហាត់ បំបាត់ សំខាន់ សម្លាប់ សំគាល់ កំណាញ់ បន្ទាល់ ក្ដាល់ ទំនាស់ ប្រញាប់ប្រញាល់ កន្តាល់ អឺរ៉ាន់ រហាត់ បំឡាក់ ស្រភន់ ប្រញាប់ ណាស់ កំចាត់កំចាយ ។

ពាក្យឥតបន្តក់– កល កុសល ផល ភន្ទ គណ ចក្ក ឆត្ត គជទន្ត ជនបទ ជប ថលបថ កម្មបថ ថលយាន ទណ្ឌ បុព្ឃា បញ្ញត្ត បុត្តភាគ ទិមិល ពលកាយ ភក្ត្រ ភត្តកាល

កាលបក្ស ប្រាកដ ប្រយ័ត្ន ប្រកប បក្ខគណនា មណ្ឌប
ពមល មាណព រក្ខ រក្ស ក្សត្រ ហរិរក្ស ។

---

## ២១ – សព្វនាម

សព្វនាមជាពាក្យតំណាងនាម ដូចពាក្យថា: ខ្ញុំ, អ្នក, ឯង, វា, គេ, នាង, លោក, ព្រះអង្គ ... ជាសព្វនាម ។ សព្វនាមមានពីរយ៉ាងគឺ បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

### បុរិសសព្វនាម

បុរិសសព្វនាមចែកជា: បឋមបុរិសៈ, មជ្ឈិមបុរិសៈ, ឧត្តមបុរិសៈ ។ បឋមបុរិសៈគឺ: វា, គាត់, គេ, នាង, លោក, ព្រះអង្គ ... ។ មជ្ឈិមបុរិសៈគឺជាសព្វនាមសំរាប់ប្រើជំនួសឈ្មោះបុគ្គល ដែលគេកំពុងតែនិយាយទៅរកក្នុងទីចំពោះមុខ ហើយនិយាយមិនចេញឈ្មោះឡើយ យកសព្វនេះជំនួស ដូចពាក្យចំពោះមុខ: ឯង, លោក, អ្នក, នាង, អា, ហាង ... តាមពាក្យទាប-ខ្ពស់-កណ្ដាល ។ ឧត្តមបុរិសៈគឺ: ខ្ញុំ, ខ្ញុំបាទ, ខ្ញុំឯង, អញ, អញខ្ញុំ, អាត្មាភាព, យើងខ្ញុំ,

យើង ... តាមពាក្យទាប-ខ្ពស់-កណ្ដាល ។ ឧទាហរណ៍ៈ កូនខ្ញុំបាទអាយុ .. ដឹងក្ដីបន្តិចហើយ ឥឡូវនេះវាទៅរៀនឯសាលា ។ មារបស់ខ្ញុំនៅភូមិឯស្រុកស្រែ គាត់បានផ្ញើដំណឹងមកថាៈ គាត់នឹងមកលេងនឹងខ្ញុំនៅថ្ងៃខាងស្អែក ។



សត្វពាហនៈគឺៈ គោ-ក្របី-ដំរី-សេះ, សត្វទាំងនោះធ្វើប្រយោជន៍ឲ្យយើង ចូរយើងថែរក្សាឲ្យល្អ ។ ទេវីម្នាក់ឈ្មោះបទុមកេសរ រត់ចេញពីនគរជាមួយនឹងស្វាមីទៅដល់កណ្ដាលព្រៃ នាងក៏ប្រសូតបុត្រ ។ ហ្វូងយានមកប្រថាប់



ក្នុងបុណ្យនេះ ទ្រង់នឹងយាងមកដោយយានសិវិកា, នាម៉ឺនសព្វមុខមន្ត្រីនៅរង់ចាំថ្វាយបង្គំព្រះអង្គ ។ អ្នកអញ្ជើញទៅកំពត នោះអ្នកនឹងទៅដោយអ្វី ! ។

កាលណាឯងទៅនៅទីក្រុង ឯងកុំដើរលេងយប់ ឯងកុំមានកៀននឹងមនុស្សគ្រាគ្រក់ ។ អាឯងឈ្មោះអ្វី? អាដែលលួចគេប៉ុន្មានដងហើយ? អាឯងមានប្រពន្ធកូនឬនៅ? ។ នៅថ្ងៃទំនេរពីថ្ងៃរៀន, ខ្ញុំឆ្លៀតទៅសួរឪពុកម្តាយរបស់ខ្ញុំ ។ ល្ងាចនេះគេនិមន្តអាត្មាភាពទៅទេសនា ។ យើងរាល់រូប តែងតែមានសេចក្តីស្លាប់ជាធម្មតានឹងជៀសពុំបាន ។

## វិសេសនសព្វនាម

វិសេសនសព្វនាម គឺជាស័ព្ទសំរាប់ប្រើជាជំនួយនាម នាមមានលំនាំជាបទវិសេសនៈ ដើម្បីនឹងមិនឲ្យប្រទំសេចក្តីក្នុងសង្កាត់នៃប្រយោគមួយៗ ។ វិសេសនសព្វនាម មានពីរយ៉ាងគឺៈ វិសេសនសព្វនាមនិយម ១, វិសេសនសព្វនាមអនិយម ១ ។ វិសេសនសព្វនាមដែលសំដែងសេចក្តីដាច់ស្រេចហៅថានិយម ។ វិសេសនសព្វនាមដែលសំដែងសេចក្តីមិនដាច់ស្រេចហៅថាអនិយម ។

វិសេសនសព្វនាមនិយមៈ នោះ, នុ៎ះ, ហ្នឹង, នេះ, មាក់, មួយទៀត, ឯនេះ, ឯណោះ (Pronom démonstratif) ។

វិសេសនសព្វនាមអនិយមៈ ឯណា, ដទៃ, ណាមួយ, ផ្សេង, ទៀត, ដូចម្ដេច, ពួកខ្លះ, អ្នកខ្លះ, ខ្លះ, ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, អ្នកណា, អ្វី, ឯទៀត ( Pronom indéfini ) ។

វចនសព្វនាមឯកវចនបឋមបុរិសៈ វា, គេ, នាង, លោក, ព្រះអង្គ, អា, មេ ... ។ ពហុវចនបឋមបុរិសៈ វាទាំងឡាយ, គេទាំងឡាយ, អស់នាង, អស់លោក ... ។

ឯកវចនមជ្ឈិមបុរិសសព្វនាមៈ អ្នក, នាង, លោក, ឯង, អា, ហង ... ។

ពហុវចនមជ្ឈិមបុរិសសព្វនាមៈ អស់អ្នក, អស់នាង, អស់លោក, ឯងទាំងអស់គ្នា, អាទាំងឡាយ ... ។

វចនឧត្តមបុរិសសព្វនាមៈ ខ្ញុំ ( ឯក. ), យើង ( ពហុ. ), យើងខ្ញុំ ( ពហុ. ) ។

វិសេសនសព្វនាមក៏មានវចនៈដូចពាក្យថាៈ នេះ ( ឯក. ), នោះៗ ( ពហុ. ), ណា ( ឯក. ), ណាៗ ( ពហុ. ), ម្នាក់ៗ ( ពហុ. ) ។

## ២២ - កិរិយាវិសេសន៍

កិរិយាវិសេសន៍ជាសព្ទបន្ថែមលើកិរិយា ដើម្បីឲ្យកិរិយាមានសព្ទ វិសេសឡើង ឬប្លែកឡើងទៀត ។ កិរិយាវិសេសន៍បន្ថែមសព្ទរបស់ គុណនាមឲ្យប្លែកឡើងដែរ ដូចបានអធិប្បាយរួចហើយៈនៅខាងលើ អំពីអតិវិសេសគុណនាមនេះឯង ។ បើកាលណាគេញែកពាក្យក្នុង បទសម្ពន្ធនោះគុណនាមនឹងកិរិយាវិសេសន៍ចងភ្ជាប់គ្នាជាបទៈហើយ ហៅថាអតិវិសេសគុណនាមក៏បាន ឬហៅញែកពីគ្នាចេញក៏បាន ។

កិរិយាវិសេសន៍ទាំងឡាយគឺ ឆាប់, ណាស់, យឺត, លឿន, មួយៗ, រឿយៗ, ទន្ទឹន, ណឹមណុម, ថិតថេរ, ស្ទើរ, រ៉ះ; ភ្លែត, ភ្លាម, ថ្លៃ, តាន់តាប់, ខ្ទាន់ខ្ទាប់, ញាប់ៗ, លបៗ, ណេះណោះ, តតាក់តតាំ, ទឹង, ទែលទល, ដរាប, នៅ, បណ្ដាប់, បន្ដោក, បន្ទុប, បន្ទិច, បន្ថែម; ញ៉ាបៗ, ប៉ុក, ប្រកិត ប្រកឹង, តូង, ប្រុស, ព្រួត, ព្រងើយ; រម៉ាំងរម៉ោក, គ្រេង, ប្រួង, ព្រឹស, ប៉ុង, គ្រាំង, តឹង... ។

ឧទាហរណ៍ ៖ ទៅឆាប់, មកក្រាម, ដើរយឺត, មើលខ្ជាន់ខ្ជាប់, ធ្វើការយ៉ាងប្រឹមប្រុម, មានជីវិតឋិតថេរ, ដេញប្រកិត, ប្រកឹងតារ, ដួលគួង. ទៅរម៉ាំងរម៉ោក, រលំគ្រេង, ទៅណេះ, ទៅណោះ. មកដកប, ជម្ងឺពុំទាន់ជានៅឡើយ, និយាយប៉ោចៗ, ដាក់ប៉ុក, រៀបបន្ទុប, អ្នកទិញមកថ្លៃបន្តិចហើយ, ដំរីរត់លឿនស្ទើរ ... ។

---

## ២៣ – វិធីប្រើអាយតនិបាត

អាយតនិបាត មានអត្ថប្រព្រឹត្តទៅតាមចំនងសេចក្ដី ដូចមានតទៅ ៖

អាយតនិបាតទី ១ – "រី" សំរាប់ប្រើជាបទប្រធាន ឬដើមបទ ។ ឧ. រីបុណ្យនិងបាប អំពើសុភាព នោះរមែងតាម... ។ រីគ្រូបាធ្យាយ ប្រដូចនូវម្ដាយ អាត្មាកងហោង ។ រីអំពើជាកុសល ជនគប្បីធ្វើ ។

អាយតនិបាតទី ២– មានអត្ថ ៥ យ៉ាង៖

១– "នូវ" សំរាប់ភ្ជាប់កម្មរបស់កិរិយាសកម្ម ។

ឧទាហរណ៍ៈ គេស្តាប់នូវធម៌, សង្ឃសំដែងនូវធម៌ ។ ប៉ុន្តែក្នុងភាសាដែលគេនិយាយជាធម្មតា គេប្រើនកាត់ពាក្យ "នូវ" ដូចគេនិយាយថាៈ គេស្តាប់ធម៌, លោកសំដែងធម៌ ។

២– "កាន់" សំរាប់ភ្ជាប់កម្មទៅកិរិយាអកម្ម ឧ. គេទៅកាន់ផ្ទះ, វាមកកាន់ផ្ទះ ។ ប៉ុន្តែតាមភាសាធម្មតាគេប្រើននិយាយកាត់បង់ដូចជាៈ ខ្ញុំទៅផ្ទះ, គេមកផ្ទះ ។

៣– "ញុំាង" ជាពាក្យទទួលសម្រេចនូវអំពើដែលគេឲ្យធ្វើ, ឧ. ពពួកសត្វផង សាហាវយង់ឃ្នង ប្រយ័ត្នញុំាងបាន...: ព្រះពុទ្ធត្រាស់ដឹងនូវអរិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង, គ្រូប្រដៅខ្លួនឯងសិស្សញុំាងសិស្សឲ្យរៀន ។

៤– "អស់" ប្រែថាទៅ រហូតដល់, ឧ. គេទៅអស់យោជន៍បី, វាទៅអស់យប់មួយ ។

៥– "នឹង" ឬ "ចំពោះ" ទទួលពាក្យដែលគេនិយាយចំពោះខ្លួន, ឧ. ខ្ញុំបាននិយាយនឹងអ្នក, - ចំពោះអ្នក, គេផ្តាំមកនឹងខ្ញុំ ។

## អាយតនិបាតទី ៣- មានអត្ថ ៦ យ៉ាង:

១- "ដោយ" ជាគ្រឿងសម្រេចនូវអំពើ ។. គេធ្វើនូវអំពើដោយកាយ ។ គេកាន់ស៊ី ៗ ដោយដៃ ។

២- "ដោយផ្លូវ" ឬ "តាម" ឬ "ដោយសារ" ជាផ្លូវជាលំនាំដែលប្លែកពីការសម្រេចនូវអំពើ ។. ព្រះពុទ្ធទ្រង់រៀនដោយនូវតេជះ, ចូរធ្វើតាមពាក្យនៃអញ, វារស់នៅដោយសារសេចក្តីទំនុកបំរុងនៃខ្ញុំ ។

៣- "គឺ" ឬ "ដែល" ជាអ្នកសម្រេចនូវអំពើអំពីខ្លួនឯង ។: ធម៌គឺការៈដែលទ្រទ្រង់, ពាក្យនេះដែលខ្ញុំបានប្រាប់ហើយ, គឺអ្នកឯងមិនត្រូវធ្វើយ៉ាងនេះទៀត, ព្រះសាស្តា គឺអ្នកទាំងឡាយគប្បីឲ្យអត់ទោស ។

៤- "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាហេតុ, ជាចំនង, ជាដំណើរ ។. បានជាគាត់នៅក្នុងទីនោះ ព្រោះតែសក្ការៈ, សត្វលោកមានចិត្តខ្ពស់ឡើងព្រោះលាភ មានចិត្តទាបចុះព្រោះខាតលាភ ។

៥– "មាន" ជាអាការៈ ។. បើបុគ្គល មានចិត្តគិតទោស ប្រទូស្តហើយ ពាលក្ដី ធ្វើក្ដី... ។

៦– "ដោយ" ប្រកបជាមួយ ។. បូរព្រមព្រៀងមួយ អន្ទើ ដោយដំណើរនោះ ។

## អាយតនិបាតទី ៤ – មានអត្ថ ៣ យ៉ាង:

១– "ដល់" ជាទីទទួលនូវអំណោយ ។. ទាយកឲ្យនូវទាន ដល់សង្ឃ, គ្រូលំបាកឲ្យផល ដល់អ្នកកំដល ។

២– "ដើម្បី" ឬ "បំរុង" ជាទីធ្វើ·បញ្ញូន ។: គេបង្គាប់មនុស្សឲ្យក្រាលនូវអាសនៈទាំងឡាយ ដើម្បី ឬ បំរុងភិក្ខុសង្ឃ, អាពុកធ្វើទៅនូវសំលៀកបំពាក់ទាំងឡាយ ដើម្បីកូន ។

៣– "ចំពោះ" ឬ "នឹង" ជាទីត្រូវគេបៀតបៀន ។. អ្នកណាប្រទូស្ត ចំពោះ ឬ នឹងមនុស្សដែលមិនប្រទូស្ត ។

## អាយតនិបាតទី ៥– មានអត្ថ ៣ យ៉ាង:

១– "អំពី" ឬ "ចាក" ។. ភ័យ អំពីសេចក្ដីស្លាប់, បុគ្គលគប្បីឃាត់នូវចិត្ត ចាកបាប គឺជាបុគ្គលគប្បីលះបង់បាប ។

២ – "ជាង" ជាដែនប្រៀបធៀបឲ្យដឹងថាលើស ឬ ថយជាងគ្នា ឧ. សីលជាគុណជាត មានផលច្រើន ជាងទាន ។

៣– "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាទីមូលហេតុ-ដើមចម ឧ. សង្គ្រាមរ៉ាំងខ្ទាយកើតព្រម ព្រោះសេចក្ដីល្ងង់នាំការឲ្យកើត ។

## អាយតនិបាតទី ៦– មានសព្ទ ៥ ម៉ាត់ៈ

១ – "នៃ" ឬ "របស់" ជាគ្រឿងភ្ជាប់ដោយម្ចាស់ ឧ. ផ្ទះ នៃអ្នកស្រែ ឬ របស់អ្នកស្រែ ។

២ – "នៃ" ជាគ្រឿងភ្ជាប់ដោយពួក-ដោយក្រុម ឧ: ប្រជុំ នៃជនទាំងឡាយ ហ្វូង នៃគោទាំងឡាយ ។

៣ – "នៃ" ជាគ្រឿងភ្ជាប់ដោយការសម្គាល់ដើម ឧ. ការៈ នៃអគ្គ គឺគុណបុគ្គលឃ្លើមិនបានដោយគម្រប, កិច្ចដោយប្រថ័បមិនបានឡើយ ព្រោះការៈ នៃតន្ទ្រីព្រះអាទិត្យមានកុន កាលសម្ភ្លេះ ។

៤- "កាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីដែលគប្បីមកប្រើហាក់ដូចជាបកប្រែបានដោយឡែក ៖ កាលដែលតារកកំពុងយំ បិតាចេញទៅហើយ, អ្នកទាំងឡាយចូររង់ចាំក្នុងទីនុ៎ះបន្តិចសិន, កាលបើខ្ញុំនិយាយថា៖ អ្នកទាំងឡាយចូរចូលមកចុះចូរមកឲ្យឆាប់ ។

៥- "ដ៏គុំ" ឬ "បណ្ដា" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួម ដែលប្រមូល ។. បណ្ដាមនុស្សទាំងឡាយ ក្សត្រិយ៍ក្លៀវក្លាបំផុត ។

## អាយតនិបាតទី ៣ - មានអត្ថ ៩ យ៉ាង៖

១- "ក្នុង" ជាទីកំបាំង ។. គេអង្គុយក្នុងខាងក្នុងនៃបន្ទប់ ។

២- "ក្នុង" ជាទីដែលជ្រាប ឬ លាយគ្នា ។. ប្រេងស្ថិតនៅក្នុងល្ងទាំងឡាយ, ទឹកដោះស្រស់ស្ថិតនៅក្នុងទឹក ។

៣- "ក្នុង" ជាទីអាស្រ័យ ។ ត្រីទាំងឡាយនៅក្នុងទឹក ។

៤– "ក្នុង" ជាកាល ជាពេល ។. កុសលចិត្ត ជាចិត្ត កើតឡើងហើយមានក្នុងសម័យឯណា ។

៥– "លើ" ឬ "ក្បង់" ឬ "ត្រង់" ឬ "ឯ" ជាទីនៅ-ទ្រ-ទ្រាប់-ទៀតផ្ទែក ។. ព្រះអង្គមានព្រះភាគគង់ហើយលើអាកាស ដែលគេក្រាលហើយ, ពោមទាំងឡាយពួជក្រៀន ឬ គ្រាន់ក្រៀន ។

៦– "នាកាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីដែលចូលប្រហែលដូចជាបទប្រធាន ។. នាកាល ព្រះអាទិត្យអស្ដង្គតហើយ ព្រះចន្ទរះឡើង, កាលបើយាំងនេះមាន មានតែយើងកុំទៅ, កាលដែលមាណពនោះនិយាយប្រាប់ទៅ សរីរៈទាំងអស់នៃព្រាហ្មណ៍ ពេញប្រៀបផ្សាយហើយដោយបីតិ ។

៧– "និមិត្ត" ជាគ្រឿងចំណាំ-ជាហេតុ ។. ដូចនឹង សម្លាប់ និមិត្តក្អក (ព្រោះក្អក-ព្រោះតែក្អក) ។

៨– "ជុំនុំ" ឬ "បណ្ដា" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួមដែលប្រមូលគ្នា ។. ជុំនុំឬបណ្ដាភិក្ខុទាំងឡាយពីររូបនោះ ភិក្ខុមួយរូបដល់ហើយនូវសោតាបត្តិផល ។

៩– "ជិត" ឬ "ទៀប" ជាទីជិត-ប្រប ឧ. ស្រុកពាំងយជិតក្រុង ឬ ទៀបក្រុង, ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។

អាលបនៈ – អាលបនៈ ជាពាក្យសម្រាប់ប្រើជាសំដីស្រែកហៅ ឬ ពោលចំពោះ មានអាការៈដូចស្រែកហៅ ដូចពាក្យថា: "បពិត្រ, ម្នាល, នែ, ហៃ" តាមសេចក្ដីគោរព ឬ ពាក្យគោរព ឧ. បពិត្រមហារាជ សូមព្រះអង្គដ៏ចំរើនទ្រង់ឈ្នះ, ម្នាល ឬ នែកូនបូកុំទៅ... ។

## ២៤– និបាតស័ព្ទ

និបាតជាស័ព្ទសំរាប់ផ្សំដីត្រង់ឃ្លាល្បះមួយៗ ជាជំនួយនាមស័ព្ទនឹងកិរិយាស័ព្ទ ឲ្យមានសេចក្ដីស្រឡះ ច្បាស់លាស់ពិរោះស្រួលស្ដាប់ ដូចពាក្យថា: ក៏ - ក៏ដោយ - ក៏ដែរ - ដែរ - ផង - ឯ - បើ - ទោះ - ទោះបី - បើទុកជា - ទើប - ពុំនោះសោត - ពាល - ល្គឹកតែ - ព្រោះ - ឥឡិត ជាដើម ។ និបាតសំ

មានច្រើនយ៉ាងគឺ៖ អាយតនិបាតជាសព្ទសំរាប់ចងក្រងពាក្យ ដែលជាកម្មរបស់កិរិយា ឬជាពាក្យបំពេញបទរបស់នាមនាម ដូចពាក្យថា៖ ខ្ញុំស្ដាប់នូវពាក្យ, វាទៅកាន់ផ្ទះ, កូនរបស់ខ្ញុំ, ភូមិផង, យើង ... ៖ ពាក្យ៖ នូវ, កាន់, របស់, នៃ... ជាអាយតនិបាត ៗ អាយតនិបាតទាំងឡាយគឺ៖ រី, នូវ, កាន់, អស់, ញុំាង, ចំពោះ, ដោយ, គឺ, ហេតុ, ព្រោះ, ដល់, ចំរុង, អំពី, របស់, នៃ, កាលបើ, ទៀប, ជិត, និមិត្ត ៗ (ដូចមានពិស្ដារក្នុងខាងលើ)

## និបាតប្រាប់កាល - ប្រាប់ពេល (កាលត្ថទីបកៈ)

គ្រានោះ, លំដាប់នោះ, ដងនោះ, កាលនោះ, ក្សណនោះ, ព្រឹក, អំពីព្រឹក, ថ្ងៃ, ក្នុងវេលាថ្ងៃ, ល្ងាច, វេលាល្ងាច, ម្សិល, ម្សិលម៉ិញ, ពីម្សិលមិញ, ស្អែក, ខានស្អែក, ខានស្អែកមួយ, អម្បាញ់មិញ, ក្លាយ, រំពេច, សិន, តទៅ, ក្នុងខាងមុខ ៗល ៗ

## និបាតប្រាប់ទី (ឋានត្ថទីបកៈ)

ខាងលើ, ខាងក្រោម, ខាងក្រោយ, ខាងក្នុង, ខាងក្រៅ, ចន្លោះ, រវាង, ស្ងាត់, ទីស្ងាត់, កំបាំង, កំបាំងពីមុខ, ចំពោះមុខ, នៅមុខ,

ដទៃ, ឯមុខ, ឯនាយ, ឯអាយ, ខាងនាយ, អាយ ។ល។

## និបាតប្រាប់សេចក្ដីប្រៀបប្រដូច (ឧបមេយ្យត្ថវាចកៈ)

ដូច, ដូចជា, បីដូច, ហាក់ដូច, ប្រដូច ប្រហែលដូច, យ៉ាងណា, យ៉ាងណាមិញ, យ៉ាងនេះ, យ៉ាងនោះ, ដូច្នេះ, ដូច្នោះ, ដូចម្ដេចមិញ ។ល។

## និបាតប្រាប់ប្រការ (ប្រការត្ថវាចកៈ)

ម្ដេច, ដូចម្ដេច, ដោយប្រការដូចម្ដេច, ដោយប្រការនោះ ។ល។

## និបាតប្រាប់សេចក្ដីឃាត់ហាមដាច់ខាត

(បដិសេធនត្ថវាចកៈ)

កុំ, ពុំ, មិន, អត់, ខាន, ឥត, មែន, តែប៉ុណ្ណោះ, គ្រាន់តែ, មិនមែន, មែនពិត, វៀរលែង, វៀរលែងតែ, លើកលែងតែ, កុំឡើយ, ណ្ហើយ, ល្មមហើយ ។ល។

## និបាតប្រាប់សេចក្ដីតាមបានឮ (អនុស្សវនត្ថវាចកៈ)

ឮថា, បានឮថា, មានដំណាលថា ។ល។

## និបាតប្រាប់សេចក្ដីជញ្ជឹង - ប្រមើល - ស្មាន - ណាត់

( បរិកប្បត្ថវាចកៈ )

បើ, បើថា, ប្រសិនបើ, ទោះបី, ល្គឹកកែ, បើដូច្នោះ, ធ្វើដូច, ម្ដេចហ្ន៎ ។ល។

## និបាតប្រាប់សេចក្ដីសួរដំណឹង ( បុច្ឆនត្ថវាចកៈ )

ឬ, ឬក៏, ឬអ្វី, ឬទេ, ដូចម្ដេច, ដែរឬ, យ៉ាងដូចម្ដេច, យ៉ាងណា, ទដឹង, យ៉ាងណានេះ, អេះ, ហ៎, ហ្ន៎, ។ល។

## និបាតប្រាប់សេចក្ដីឆ្លើយ - ទទួល (សម្បដិច្ឆនត្ថវាចកៈ)

អើ, បាទ, ព្រះបាទ, ព្រះបាទម្ចាស់, ករុណា, ករុណាពិសេស, ចា៎ះ, ច៎ះ, ពរម្ចាស់, ម៉ែ, ព្រះម៉ែម្ចាស់, ចំរើនពរ, ថ្វាយព្រះពរ ។ល។

## និបាតប្រាប់សេចក្ដីតឿន ( ឧយ្យោជនត្ថវាចកៈ )

ហ៎, ដូចជាតឿន, ឆាប់ៗ ។ល។

## និបាតប្រាប់សេចក្ដីច្រើនយ៉ាង ( អនេកត្ថវាចកៈ )

ក៏, ឯ, ផ្សិត, ក្ដី, ផង, មួយ, វុះ, ឬ, ពិត, មែន, ដែរ, អើក៏, មែនពិត, ពីព្រោះ, ក៏ដោយ, ក៏បាន, ពុំនោះ-

សោតមួយវិញទៀត, ចំណែកខាង. ប៉ុន្តែ, ប៉ុន្តែថា, ថ្វីបើ,

ក្រែង, ដូចជា, ម្យ៉ាងទៀត ។ល។

## និបាតប្រាប់សេចក្តីគ្រាន់តែបំពេញបទ (បទបូរណត្ថវាចកៈ)

ហ្ន, ហ៎, ហះ, យី, អេយី, ឯង, ទេ, យីតើ ។ល។

## និបាតប្រាប់សេចក្តីផ្សេងៗ (នានត្ថវាចកៈ)

មិន, ខុស, ទទេ, ទៀត, វិញ, ខ្ពស់, តាម, ប្រាកដ, ដោយពិត, ទវិញទៀត, ក្រៃពេក, ក្រៃលែង, រឿយៗ, ញឹកញយ, ជាក់លាក់. ពិតម្ពាយ, ក៏មិនហើយ, សូម្បី, តិចតួច, ចាប់ដើម, តាំងពី, ពីដូច, ពុំហាក, មួយគ្រា, ម្តង, តិចៗ, សន្សឹម, សំរៀម, ថមៗ, ញឹបៗ, មួយរយដង, មួយអន្ទើ, ជាមួយ, ខ្លួនឯង ។ល។

## និបាតប្រាប់សេចក្តី (ជាកាលបទៈ)

សំរាប់អ្នកគ្មានកេរ្តិ៍ ទៅកាន់អ្នកមានកេរ្តិ៍ ឬអ្នកមានកេរ្តិ៍ ទៅកាន់អ្នកគ្មានកេរ្តិ៍ ។

(កាលបន្តក្រិយា:) សូមព្រះតេជះ, សូមព្រះតេជះជាគល់លើត្បូង, សូមទ្រង់មេត្តាប្រោស, សូមទានមេត្តាប្រោស, ទានប្រោស, បពិត្រព្រះអង្គ, បពិត្រព្រះករុណា, បពិត្រលោកដ៏ចំរើន, នែនាយ, នែចៅ, ព្រះវស្ដង, រី, រីយ, នែអ្នកដ៏មានអាយុ, នែអ្នកដ៏ចំរើន, អស់លោកទាំងឡាយ ។ នាង អានាង... ។ល។

## ឧទានសព្ទ

សព្ទសម្រាប់ប្រាប់សូរសំឡេង ឬជាសម្ដីភ្ញាក់មាត់ដោយភ្ញាក់ផ្អើល ព្រោះមានភ័យ ឬមានសេចក្ដីត្រេកអរត្រេកពេក ។ ម៉ឹក! ប៉ុង! ត្រាំង! ប្រឹមៗ! គឹង! វីកៗ! ប៉ាំង! ខូនខូង! ពុទ្ធោ! កម្ម! ។ល។

## បរិវារសព្ទ

មានពាក្យខ្លះឥតសព្ទប្រែ សំរាប់តែបន្ថែមសំដី ពាក្យទាំងនោះហៅថាបរិវារសព្ទ ។ ជាធម្មតា បរិវារសព្ទភ្ជាប់នឹងនាម ឬនឹងគុណនាម មានលំនាំដូចអតិវិសេសគុណនាម ។ ពាក្យទាំងនោះគឺ: ប្រអប់ប្រឡូង, ចានក្បាន, ផ្ទះសម្បែង, សួសុក,

ចំណីចំណុក, ព្រៃផ្សៃ, គោអំពែ, សេះអំពែះ, មនុស្សម្នា, ចិនព្រិន, យួនព្រួន, ម៉ោះម៉ា, ក្មេងក្មាង, ថ្នាំសង្កូវ, ស្មៅព្រៅ, ដំណាំដំណោប, សត្វពន្ទាត់, នំនែក, ឧស្សាហ៍អាសាញ់, ស្គុះស្គាយ, ស្គោកស្គាំង, ក្ងង់ក្ងាត់, ដំបងព្រនង់ ។

## ២៥ – សំខ្យា ឬ សំខ្យាស័ព្ទ

សព្ទសំរាប់រាប់នាមហៅថាសំខ្យាស័ព្ទ ។ សំខ្យាស័ព្ទមាន ពីរយ៉ាងគឺ បកតិសំខ្យា និងបូរណសំខ្យា ។

### បកតិសំខ្យា

សំខ្យា ដែលរាប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមនាមថា ប៉ុណ្ណេះ ប៉ុណ្ណោះ ដូចរាប់ថា: មួយ - ពីរ - បី - បួន - ប្រាំជាដើម ហៅថាបកតិសំខ្យា ។

### បូរណសំខ្យា

សំខ្យាដែលរាប់នាមនាមបន្តិចជាជាន់ៗ តាមលំដាប់តាមថ្នាក់ ដូចពាក្យថា ដំបូង (ទីមួយ) - គំរប់ពីរ - គំរប់បី - គំរប់បួន - គំរប់ប្រាំ

ជាដើមទីនំពាក្យថា: បឋម: - ទុតិយ: - ចតុត្ថ: - បញ្ចម: - ឆដ្ឋ: ហៅថាបូរណសំខ្យា ។

បកតិសំខ្យាមានពីរពួកគឺ: សំខ្យាសព្ទនាម១, សំខ្យាគុណនាម ១ ។ សំខ្យាសព្ទនាមមានបួនគឺ: មួយ - ពីរ - បី - បួន ។

សំខ្យាសព្ទតាំងពីប្រាំតទៅសឹងជាគុណនាមទាំងអស់ ។ ឯបូរណសំខ្យាជាគុណនាមទាំងអស់ដែរ ។

វិធីប្រើសំខ្យាសព្ទ — នឹងរាប់វត្ថុៗ គេដាក់សំខ្យានៅពីក្រោយនាមនាម ឬភ្ជាប់ខាងមុខនាមនាម តាមដោយចំនួនស្រួលជាក្នុងភាសា ។ ដូចរាប់ថា ១ រៀល - ពីររៀល - មួយពាន់ម៉ែត្រ - មួយសែនហាប - មួយលាននាក់:.. គោពីរ - សេះហុកសិប - ឥដ្ឋមួយម៉ឺន - ពាហនមួយកោដិ - ស្វាយប្រាំស៊ឹក ... កូនជម្រង - ថ្នាក់បន្ទាប់ - សេចក្តីគំរប់ប្រាំពីរ - បឋមដ្ឋាន - បឋមាសាឍ - ទុតិយវិជ្ជា • បញ្ចមី • ពោសថ ។ល។

## ២៦ -- បុព្វបទ

អ (សំរាប់បដិសេធ) ស័ព្ទ «អ» ជា ប័ព្វ បំរាប់បដិសេធ ។ «អ» បដិសេធនេះសំរាប់ប្រើភ្ជាប់នឹងស័ព្ទដទៃ សេចក្ដីមានន័យថា: ពុំ-មិន-ឥត-មិនមែន ដូចពាក្យ: អកតញ្ញូ-អភ័ព្វ-អកុសល-អភ័យ-អទុក្ខ-អរោគ-អនត្តា-អកម្ម-អគតិ-អគោចរ... ជាដើម ។ «អ» បដិសេធនេះប្រើជាបុព្វបទហៅថា «អ» បុព្វបទ ។ មានបុព្វបទពួកមួយទៀត សំរាប់ប្រើភ្ជាប់ខាងដើមពាក្យ ។ បុព្វបទទាំងនោះមានន័យថា ឲ្យ... ធ្វើឲ្យ... ដូចពាក្យថា: កកាយ - បញ្ចូល - បណ្ដេញ - បង្អិល - បន្ធូរ - បន្ទយ - បង្ហួម - បណ្ដើរ - ទទាស់ទទែង - បង្ក្រាប - បំបោល - បញ្ជ្រាប - បង្រៀន... ជាដើម សឹងជាពាក្យផ្ដើមដោយបុព្វបទ ក បញ្ញ បណ បន ញ ទ បំបង... ។

## ២៧ -- អាគម

គេហៅថាអាគម គឺអក្សរបុះថែមត្រង់ចន្លោះដូចពាក្យថា: ចតុរង្គ-និរន្តរ-បរិយោសាន-ចតុរារិយសច្ច... ។ ចតុ-អង្គ ជាចតុរ-អង្គ ជាចតុរង្គ, និ-អន្តរ ជានិរ-អន្តរ ជានិរន្តរ, បរិ-ឱសាន ជាបរិយ-ឱសាន ជាបរិយោសាន, ចតុ-អរិយសច្ច ជាចតុរ-អរិយសច្ច ជាចតុ-រារិយសច្ច, អក្សរ រ-យ ដែលយកមកថែមដើម្បីសំរួលស័ព្ទអាន ហៅថា អាគម ។ អាគម សំរាប់ប្រើតែក្នុងភាសាបាលី និងភាសាសំស្រ្កឹត នោះអក្សរដែលយកមកប្រើជាអាគមមានចំនួនសំរេច ។

## ២៨-- ឧបសគ្គៈ

ឧបសគ្គ ជានិបាត និងជាអព្យយស័ព្ទ ( ពាក្យមិនផ្លាស់ប្តូររូបនិងស័ព្ទ) ដូចជានិបាតនានាដែរ តែពួកនិបាតដែលហៅថា

ឧបសគ្គៈនោះ មានចំនួនតែ ២០ ស័ព្ទ ហើយមានរបៀបបែបផែនក្នុងវិធីបង្កើតពាក្យដោយឡែកផ្សេងពីនិបាតនានា ។ ក្នុងការបង្កើតភ្ជាប់ពាក្យ គេដាក់ឧបសគ្គៈជាខាងដើមនាមស័ព្ទ រឺកិរិយាស័ព្ទ ។

ឧបសគ្គៈទាំង ២០ ស័ព្ទគឺៈ

អតិ ប្រែថា ក្រៃ - ក្រៃ - ក្រៃពេក - ពេក...

អធិ – ក្រៃលែង - ក្រៃពេក - លើសលុប - លើសលែង - សង្កត់

អនុ – តាម - តូច - បន្ទាប់ - រង - ក្រោយ - បណ្តោយ - លំដាប់

អប – ប្រាស - គេច - វៀស ...

អបិឬបិ – ជិត - ខាងលើ...

អភិ – ក្រៃពេក - ធំ - ចំពោះ - ឆ្ពោះ - ខាងមុខ ...

អវឬវ – ចុះ - ចុះក្រោម - ថយ - ស្រេច...

អា – ទូទៅ - សព្វ - ក្រៃលែង ...

ឧ – ឡើង - ខ្ពស់ - ក្រៅ...

ឧប – ជិត - ចូលទៅជិត - មាំ - ស៊ប់...

ទុ – អាក្រក់ - ក្រ - កម្រ - លំបាក...

ប្រែថា ចេញ - មិនសល់ - មិនមាន - ឥត ...

និ — ចេញ - ចូល - ចុះ ...

ប — ឆ្ពោះទៅ - ខាងមុខ - ចេញ មុខ ...

បដិ-បតិ — ចំពោះ - តប - ត - ប្រាស - ត្រឡប់ ...

បុរ — ខាងមុខ ...

បរិ — ជុំ - ជុំវិញ - គ្រប់គ្រាន់ - ស្រេច ..

វិ — ផ្សេង - វែក - ច្បាស់ - ជាក់ - ប្លែក ...

សំ — ព្រម - ជាមួយ - ល្អ - ប្រពៃ ...

សុ — ងាយ - ស្រួល - ស្រណុក - ល្អ - ប្រពៃ - ណាស់ - ម៉េះ ...

ពាក្យដូចមានតទៅនេះជាពាក្យមានឧបសគ្គៈ

បរិបូណ៌ ទុគត (ទុគ្គត) បរាជ័យ - អនុគ្រោះ - អភិបាល - អធិការ - អវសាន - (បរិ-ឧសាន) បរិយោសាន - ឧបាជ - និរភ័យ - អធិបតី - វិកាល - វិបរិត - សុវិជ្ជា - ទុវិជ្ជា - អបរាជ័យ - និរន្តរ - និរទោស - អជិជ័យ - អនុនាយក - អនុស្សាវនា - សុគតិ - សុគន្ធ - វិជ័យ - ទុក្ខិត ... ។

## ២៩— សម្ពន្ធ

សម្ពន្ធជាការរៀបចំនៃបទក្នុងប្រយោគ ៗ ដើម្បីភ្ជាប់ពាក្យទាំងជាបទក្នុងសង្កាត់មួយ ៗ ក្នុងប្រយោគមួយ ត្រូវឲ្យដឹងថាបទណា នូវបួលទៅរកបទណា តាមលំនាំវេយ្យាករណ៍ ៗ

ឧទាហរណ៍: ១ — " ឈ្មួញ ដឹក ស្រូវ "

ឈ្មួញ : នាម, សាធារណៈ, ឯកវចនៈ, បឋមបុរសៈជាប្រធានរបស់កិរិយា ដឹក ៗ

ដឹក : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ៗ

ស្រូវ : នាម, សាធារណៈ កម្មនៃអំពើ ដឹក ៗ

២ — " ស្ត្រី ៗ ទូល បន្លែ ដោយ កញ្ជើ "



ស្ត្រី ៗ, នាម, សាធា. ពហុ.

បឋមបុរសៈ ជាប្រធានរបស់

កិរិយា ទូល ៗ

ទូល : សកម្មកិរិយា, បច្ចុប្បន្នកាល, ពហុ ។

បរទ្វ : នាម, សាធា. ពហុ. កម្មរងអំពើកិរិយា ទូល ។

ដោយ : ការកនិបាត

តេស្ឌី : នាម, សាធា. ឯក. អកម្មរងអំពើ ទូល ។

" បងខ្ញុំ សង់ ផ្ទះថ្មីមួយ នៅផ្លូវនរោត្តម "

បងខ្ញុំ : បទមផ្សេលុប (កាត់បទពីបងរបស់ខ្ញុំ ឬបងនៃខ្ញុំ),

នាម, សាធា. ឯក. បឋមបុរស: ជាប្រធានកិរិយា សង់ ។

សង់ : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ផ្ទះ : នាម, សាធា. ឯក: កម្មរងអំពើ សង់ ។

ថ្មី : បកតិគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

មួយ : សំខ្យាគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

នៅ : និបាតប្រាប់ទី ។

ផ្លូវនរោត្តម នាម: អសាធា. ឯក. អកម្មរងអំពើ សង់ ។

## ៤ — "ឯង កុំដើរលេង ឡើយ"

ឯង: មជ្ឈិមបុរិសៈ (ម. បុ. ឯក) ប្រធាន ដើរ

លេង: ឯក. ។

ដើរលេង: អកម្មកិរិយា, ឯក. បច្ចុប្បន្នកាល ។

កុំឡើយ: និបាត បដិសេធ (បដិសេធនត្ថបទៈ)

## វិធីហាត់

១ – ចូរដាក់លិង្គទៅតាមមុខនាមនិមួយៗ ។ ឧបមាដូច ប្រុស (បុំលិង្គ) ស្រី (ឥត្ថីលិង្គ)

| | | |
|---|---|---|
| ប្រុស... | យក្ខ, យក្ស... | ភិខិន .. |
| ស្រី..., | យក្សា... | ភិខិនី ... |
| ឪពុក... | យក្ខិនី... | ទេវ... |
| ម្ដាយ... | យក្សិណី... | ម្រាក់... |
| មា... | ទេវបុត្ត... | ពាជី ... |
| មីង... | ទេវធីតា... | ពាជិនី ... |

| | | |
|---|---|---|
| តា ... | នាងមេខលា ... | គាវី ... |
| យាយ ... | កិន្នរ ... | ពានរ ... |
| កុមារ ... | កិន្នក ... | ពានរី ... |
| កុមារក ... | កិន្នរី ... | ទាយក ... |
| កុមារី ... | បក្ខ, បក្សា ... | ទាយិកា ... |
| ភិក្ខុ ... | បក្សី ... | ឧបាសក ... |
| ភិក្ខុនី ... | ព្រាហ្មណ៍ ... | ឧបាសិកា .. |
| សាមណេរ ... | ព្រាហ្មណី ... | សិក្ខមានា ... |
| សាមណេរក ... | តោក ... | ទាសី ... |
| សាមណេរី ... | តោរី ... | ទាសា ... |

២– ចូរដាក់វចនៈ ត្រង់ពាក្យនាមនាមនិមួយៗ ៗ បែបដូចមនុស្សទាំងឡាយ (ពហុវចនៈ ឬពហុ.) របស់, ( ឯកវចនៈ ឬឯក.)

មនុស្សទាំងឡាយ ... សិស្សានុសិស្ស ...

ឈើ ... កស្ត្រប្រជា ...

## ៦២ – ហ្វឹក មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

ក្មេង ... ជនានុជន ...

ផ្លែទាំងឡាយ ... ឋានានុក្រម ...

រាជាទាំងឡាយ ... របស់ទាំងឡាយ ...

សេះប្រាំ ... ពស្ត្រា ...

ដំរី ... ផ្ទះទាំងឡាយ ...

រទេះទាំងឡាយ ... ព្រាហ្មណ៍ ...

ចូស្សៀ ... ភោជនាហារ ...

កុមារ ... ទោសានុទោស ...

### ៣ - បកតិគុណនាម

| | | | |
|---|---|---|---|
| ល្អ | ប្រសប់ | ខ្ពស់ | រាវ |
| មាំ | ស្រួយ | ទាប | ខាប់ |
| ជាប់ | ធុយ | ស្អើត | ក្រអូប |
| ស្គម | រឹង | គំរក់ | ស្អុយ |
| ត្លៃក | ទន់ | ភ្លឺ | ស្រួច |

| | | | |
|---|---|---|---|
| ធាត់ | ធំ | ស្រគាប់ | តាល |
| ស | តូច | ខ្លី | គ្រន់ |
| ខ្មៅ | ស្តើង | វែង | វៀច |

៤- ចូរភ្ជាប់គុណនាមដូចមានខាងលើ នឹងនាមនាមមួយៗ តាមសមគួរ ៗ ឧបមាដូច: ទន្លេវែង - ក្មេងគំរក់ - ចុងកាំបិត... ។

| | | |
|---|---|---|
| ទន្លេ... | ភ្នំ... | បន្ទាត់... |
| ក្មេង... | ពស់... | ផ្លូវ... |
| របង... | ស្លឹក... | មួក... |
| ឈើ... | មេឃ... | ជគ្រ... |
| ឆ្កែ... | កន្ទែង... | ទឹក... |
| មេទាហាន... | ពង... | ក្តារ... |
| ក្រដាស... | មនុស្ស... | ដែក... |
| ស្បែង... | ភ្លើង... | ដាងចង... |
| ផាង... | កញ្ចក់... | កែវ... |

| | | |
|---|---|---|
| ដស ... | ចង្អុលដៃ ... | ព្រះអាទិត្យ ... |
| ឥដ្ឋ ... | វត្ត ... | ពាន ... |
| ថ្ម ... | ផ្កា ... | ក្រមួន ... |
| ពូក ... | កន្ទេល ... | ដំបៅ ... |

## ៥– អតិវិសេសគុណនាម

| | | | |
|---|---|---|---|
| ខ្មៅណាស់ | លឿនក្រៃ | ស្អុយខ្លោក | តឹងម៉ឹង |
| ម៉ដ្ឋសុង | ខ្ពស់ត្រដែត | ធំធេង | ណែនតាន់ |
| ភ្លឺរលោង | ខ្ចីក្រឡុញ | សក្បុស | ពបធេង |
| ថ្លាយង់ | ឆើតឆាយ | ខៀវស្រងាត់ | ស្ដើងហៀវ |
| រហ័សប្រិល | ឆ្ងាយសន្ទឹម | ផុយរគម | មូលក្រឡង់ |

៦– ឲ្យនាមនាមទាំងនេះ ប្រដាប់លក្ខណៈតាមគួរសម នឹងអតិវិសេសគុណនាមខាងលើនោះឯង ។ ឧទាហរណ៍ : សក់ ខ្មៅរលីង ... ៗ

សក់មានពណ៌ ... វាលផ្កាយណ៍ផាវាល ...

| | |
|---|---|
| ក្មេងនេះមានសាច់... | បានជាវត្ត ... |
| ខ្ញុំមានតុ... | មើលទៅឃើញភូមិ... |
| ទឹកនេះ... | ភ្នំនោះមានពណ៌ ... |
| មនុស្សនេះ ... | អម្បោះជាសរសៃ ... |
| ព្រាយហោះ... | គេបងចំណាង ... |
| ខ្វែងឡើង ... | កែបនេះប្រកគរ ... |
| ម្រាមដៃក្មេង ... | ភូមិនេះសង់លើដី ... |
| កងរបស់កុមារនេះ ... | ជញ្ជាំងផ្ទះនេះធ្វើនឹងក្ដារ ... |
| ព្រៃនោះ ... | ព្រះអាទិត្យមានរង់ ... |

## ៧ – វិសេសគុណនាម

| | | | |
|---|---|---|---|
| បេះជាង | ប្រសប់ជាង | ជាប់ជាង | ខ្មៅលើស |
| យឺតជាង | រហ័សជាង | ផុយជាង | សប្លែក |
| ល្អប្លែក | ខ្ពស់លើស | រឹងជាង | ល្អិតជាង |
| ថ្លាជាង | ធាត់ប្លែក | ទន់ជាង | ទាបជាង |

៨– ចូរដាក់លក្ខណៈនាមសមគួរ នឹងពាក្យនីមួយៗ ដោយវិសេសគុណនាមខាងលើ ។ ឧទាហរណ៍: ក្មេងនេះប្រសប់ជាង, កូនសិស្សនោះឆ្លាតជាង ... ។

ក្មេងទាំងឡាយ ក្មេងនេះ ... ។ ឈើជាប់នោះផ្លិកជាឈើ ... ។ យានទាំងឡាយ រទេះគោ ... ។ ក្បួនពេជ្រវត្ត ... ក្បួនទាំងអស់ ។ ភ្នំនៅស្រុកខ្មែរ-កម្ពុជា ... ។ គ្មានរបស់អ្វី ... ជាងថ្ម ។ ទឹកម៉ាស៊ីន ... ទឹកស្រះៗ ដែលជាលោហធាតុ ... ធាតុឯទៀត ។ ស្បែកមនុស្សទាំងពួង ស្បែកបារាំង ... ។ គ្មានអ្វី ... លើសម្រ័ក្សណ៍ខ្មែរ ។ ធម្មជាតិល្អិត គ្មានអ្វី ... អាកាស ។ វត្តខន់នោះសំឡីជាសរសៃ ... ។

៩– នូវកិរិយាទាំងឡាយ ចូរបំបែកជាកិតនាម ឬ នាមក្រិត ។ ឧបមាដូចពាក្យៈគិត ជាគំនិត, ខ្ទប់ ជាបន្ទប់ ... ។

គិត ... កាត់ ... សិត ... គូស ...

បង ... គោស ... សូន ... កាន់ ...

ឈាន ... ដឹង ... ជួញ ... បិត ...

ដោរ ... ទោរ ... ទិញ ... គេណ ...

ដើរ ... ខ្ញុញ ... បក ... សៀក ...

ដេក ... បួស ... បុះ ... កោរ ...

ដាំ ... ប្ដូរ ... កាត់ ... គាល់ ...

ទំ ... ពូន ... រៀប ... សួរ ...

១០ – ចូរកែនាមកើតចេញពីគុណនាមមួយ ៗ នេះ ៗ

ឧបមាដូច: ធ្ងន់ ជាទម្ងន់ ... ៗ

ធ្ងន់ ... ខ្លាក់ ... ចាំ ... ធំ ...

ពាប ... ខ្វិន ... ស្អុយ ... ក្រាស់ ...

ខ្ពប់ ... ឈឺ ... ឆ្ងាប ... ខ្ពស់ ...

ស្រាល ... បេះ ... ផ្អែម ... ឆ្ងាញ់ ...

រឹង ... ថ្លៃ ... ក្ដៅ ... ខ្សត់ ...

ល្អិត ... ស្ងួត ... ចាស់ ... ពាស់ ...

ល្ងង់ ... កាច ... ល្អ ... ក្ដួច ...

## ៦៨–ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

១១– ចូរកកិរិយាកើតចេញពីពាក្យមួយៗខាងក្រោមនេះ ។

ដូចពាក្យ : ត្រង់ ជា ដំរង់ ឬ តម្រង់ . . . ។

ត្រង់ . . . ដំរៀល . . . ចំនាយ . . . ទ្រនាប់ . . .

ត្រូវ . . . បំណាញ... បំណាស់... ចំណាប់...

ដំណោះ... បំណោទ... បំណុល... ស្អាត...

ថ្វើរ... បំណាយ... អំនួត... ផ្គត់...

ចំនើប... ច្រើន... ទ្រនំ... ក្អែន...

១២– ចូរភ្ជាប់បុព្វបទ " ក-ប-ប្រ-បង-ប ញ-បណ-បន-បំ-ច-ញ " នឹងពាក្យកិរិយានីមួយៗ តាមដោយសមគួរ ។

ដូច : កាយ ជា កកាយ, ការ ជា បង្ការ ។

កាយ . . . ជូន . . . រួម . . . ជុល . . .

ការ . . . ដោរ . . . ថែម . . . មើល . . .

ខាក . . . ឈ្មោះ . . . ករ . . . ខាំ . . :

គរ . . . ឈឺ . . . ខាន . . . ខំ...

គាប់... ដេញ... ណាត់... ពាញ...

ចូល... ដើរ... ក្រុប... រួញ...

ចេញ... ដុំ... ហែរ... ពប់...

ឆ្អុក... រៀន... បិទ... ញ៉ឹម...

១៣– ចូររកបុព្វបទដែលមានន័យថា៖ "ធ្វើឲ្យ" មកភ្ជាប់ នឹងពាក្យនិមួយៗ នេះឲ្យបានដូចពាក្យ៖ "ខំ ជា បង្ខំ" ។

ខំ... រត់... រៀប... ខាំ...

កាប់... ផល់... បែក... ខូច...

ស្លាប់... ដឹង... ហាត់... រួម...

កើត... ខាន... រលំ... រឹត...

រៀន... ឡើង... យល់... ផ្សំ...

ឈឺ... ចុះ... ពប់... ដុះ...

ដេក... ភ្លឺ... សុខ... ផ្ដាច់...

ឈរ... ទុំ... ចាល់... ប្ដឹង...

១៤– ចូររកគុណនាមដោយគួរតាមការ មកបំពេញបទនៃ ពាក្យទាំងនេះៗ ឲ្យបានដូចពាក្យថា៖ "ពស់មានពិសជាសត្វកាច" ។

## ៣០ – ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន



ពស់មានពិសជាសត្វ . . . ៗ មនុស្ស . . . គឺមនុស្សដែល មានរូបអវយវៈ ៗ ខ្លាជាម្រឹគ . . . ៗ គគីរជាឈើ . . . ហើយ . . . ណាស់ ៗ ក្ងោលជាបពិត . . . . ៗ ថ្មជាធាតុមួយ . . . . ៗ មនុស្សឈឺមានកាយ . . . ៗ ផ្លែឈើទុំញោសមានក្លិន . . . ៗ អ្នកទុគ៌តជាមនុស្ស . . . ៗ ព្រះចន្ទពេញបូណ៌មីមានរង្វង់ . . . ៗ ទឹកសមុទ្រមានរសជាតិ . . . ៗ ភ្លើងជាធាតុ . . . ៗ ដែកជា លោហធាតុ . . . ៗ មេឃ . . . គឺមេឃដែលគ្មានពពក ៗ លោហធាតុ . . . គឺសំណ . . . ៗ ខ្យល់ពីងដើរជាខ្យល់ . . . ៗ ពេជ្រ ជាត្បូង . . . ហើយ . . . បំផុត ៗ ស្មៅជារុក្ខជាតិមួយ . . . បំផុត ៗ មនុស្សធ្វើការបានហ៊ានជាមនុស្ស ៗ ព្រះអាទិត្យមានរស្មី . . . ៗ

១៥ – ចូររកកិរិយា មកភ្ជាប់នឹងប្រធាន :

ឧទាហរណ៍: ព្រះអាទិត្យ បំភ្លឺ លោក...។

ព្រះអាទិត្យ...លោក ។ ជាងដែក ... លោហធាតុ នឹងស្អប់ ។ ព្រះចន្ទ្រ... យប់ ។ ជាងបាយអ... ឥដ្ឋធ្វើកំពែងវាំង ។ ព្រះធរណី... មនុស្សទូវសត្វ, ត្រីខ្យាន នៅក្នុងសំណុំព្រះពាម ។ គ្រូ... សិស្ស ។ ពស់... រវុករវក់ ។ ច្បាប់... ឲ្យយើង ប្រតិបត្តិតាម ។ អណ្តើក... ក្នុងទឹកនឹងលើគោក ។



យើង... ប្រណិប័តន៍ អាពុកម្ដាយ ។ អ្នកនេសាទ-ត្រី... សំណាញ់ ។ ជាងទង... មាសធ្វើប្រអប់ ។ ព្រានព្រៃ... សត្វនឹងស្នា ។

# ៣២ -ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន





១៦ – ចូររកប្រធានតាមសេចក្ដីភ្ជាប់នឹងកិរិយានិមួយៗនេះ ៗ

ឧទាហរណ៍ : ចោរ លួច ទ្រព្យគេ . . . ៗ

... លួចទ្រព្យគេ ៗ ... កៀរគ្រឹនឹងព្រួល ៗ

... រៀនអក្សររៀនលេខ ៗ ... បរដំរីនឹងកង្វេរ ៗ

... លេបកង្កែប ៗ ... ជាផលជាតិ ៗ ... សិក្សាធម៌ ៗ

... រស់នៅក្នុងទឹក ៗ ... ដេញទន្សាយ ៗ ... ចំឡងពាក្យដែលគ្រូបង្គាប់ ៗ ... ឈប់សំរាកក្នុងសាលាតាន ៗ

... ពន្យល់ពាក្យនៅការរៀន ៗ ... ធ្វើតាឧបំពោះសង្ឃ ៗ

... ដាំដែកនឹងញញួរ ៗ ... កយ្លួរនឹងគ្រវី ៗ ... អុំទូកនឹងច្រវា ៗ

១៧– ចូររកពាក្យផ្ទុយនឹងពាក្យទាំងនេះ :

ឧទាហរណ៍: មនុស្សផ្គត់ផ្គង់: មនុស្សខ្ជះខ្ជាយ ...។

មនុស្សផ្គត់ផ្គង់ ...។ ផ្លូវត្រង់ហើយវែង ...។ ក្មេងឧស្សាហ៍ ...។

សេះធាត់ ...។ កូនសិស្សខ្ជាប់ខ្ជួន ...។ ឈើស្ងួត ...។

ជាងប្រសប់ ...។ ដៃគរ៉ង ... សំណ ...។ មនុស្សអ្នក

មាន ...។ សាច់ស្អុយ ...។ ផ្កាចម្ប ...។ មនុស្ស

ពាល ...។ មាសលៀនចុំ ... ប្រាក់ ...។ ឆ្កែ

កាច ...។ យប់ងងឹត ... ថ្ងៃ ...។ ផ្លែឈើខ្ចី ...។

ក្របីចាញ់ក្ដៅ ... គោចាញ់ ...។ ស្បែកគគ្រាត ...។

សេះលឿន ... គោ ...។ កាំបិតមុត ...។ ខ្លាធំ

ហើយសាហាវ ... ឆ្មា ... ហើយ ...។

១៨ – ចូររកពាក្យមកបំពេញកន្លែងចន្លោះ

ជនណាប្រតិបត្តិតាមច្បាប់នឹងបានសុខ, ជនណា ... ច្បាប់ នឹងមានទោស ។ ក្នុងសម័យដែលស្រុកសុខ, ការទាំងពួងបានចំរើន ។ ក្នុងសម័យដែលស្រុកមាន ..., ការទាំងពួងនឹងអន្តរាយ ។

មនុស្សណាដែលគិតតែសុខ, អ្នកនោះនឹងបាន... ។ នរណាយកទុក្ខមកជាទីតាំង, អ្នកនោះនឹងបាន... ។ ជនណាឃើញខ្លួនឯងជាមនុស្សក្រ, ជននោះនឹងជាអ្នក... ។ ជនណាឃើញខ្លួនឯងជាអ្នកប្រាជ្ញ, ជននោះជាបុគ្គល ... ។ នរណាតាំងខ្លួនជាខ្ញុំ, នរណានោះជាអ្នក ... ។

១៩ – ចូររើសរកពាក្យដែលមានន័យប្រហែលគ្នា (វេវចនៈ) នឹងពាក្យដូចមានតទៅ ៖

ឧបមាដូច: ចរ គឺ ត្រាច់ - ទៅ - យាង - និមន្ត ...

| | | | |
|---|---|---|---|
| ចរ... | យំ... | សំដៅ ... | បញ្ជូន ... |
| ដេក ... | ទិញ... | បិទ ... | ប្ដឹង... |
| ស៊ី... | ឲ្យ... | ដក... | ប្រដៅ... |
| មើល... | លេង... | លុប... | កាត់... |
| គិត... | ឈឺ... | បំពេញ... | បំភ្លឺ... |

# ៣០ - សមាសនាម

នាមនាមមានច្រើនយ៉ាង ។ នាមដែលកើតឡើងឯង ៗ ហៅជាបកតិនាមដូចពាក្យៈ ផ្ទះ-សេះ-ដី... ។ នាមដែលបែកចេញពីកិរិយា ឬគុណនាមហៅជានាមក្រិត ឬកិតនាម ដូចពាក្យៈ ដំណើរ-ទម្ងន់ ( មកពីដើរ - ពីធ្ងន់ ) ។

នាមដែលភ្ជាប់គួបគ្នាពីរពាក្យ ឬច្រើនពាក្យជានាមមួយ ហៅជាសមាសនាម ។ សមាសនាមជានាមគួបគ្នាដោយ នាមនឹងនាមក៏មាន, ដោយនាមនឹងគុណនាមក៏មាន ដោយនាមនឹងកិរិយាក៏មាន, ដោយកិរិយានឹងកិរិយាក៏មាន; សមាសនាមមានពីរយ៉ាងគឺៈ នាមសមាសបាលី ១, នាមសមាសខ្មែរ ១ ។ នូវនាមសមាសបាលី បើកាលណាពាក្យដែលមកមកភ្ជាប់ ជាពាក្យកើតឡើងអំពីស្រៈពេញត្រូវផ្លាស់ស្រៈនោះជាស្រៈទិសស្រ័យ ឧបមាដូចពាក្យៈ "គជ-ឥន្ទ្រ ជាគជេន្ទ្រ" "ជន-អធិបតី ជាជនាធិបតី" ។ សមាស-នាមទាំងឡាយគឺៈ ផ្លូវទាង-ពស់វែក-ក្រដាសប៉ុយ-ជើងម៉ា-

# ៣៦ — ថ្នាក់ មធ្យមដ្ឋាន នឹង ឧត្តមដ្ឋាន

គ្រប់ស្នួច - គោសៀម - ថ្នាំកុឡា - ឥណ្ឌារ - ជនានុជន - សិក្ខាធិការ - លោកុត្តរ - សាសនាចារ្យ - ទេវិន្ទ ... ។

## វិធីហាត់

ចូរសរសេរត្រូវសមាសនាមដូចមានខាងក្រោម :

សិស្ស + អនុសិស្ស = សិស្សានុសិស្ស ។ លោក + ឧត្តរ = ... ។ ជន + អនុជន = ... ។ លោក + ឥស្សរៈ = ... ។ គុណ + កនិសម្ព័ន្ធ = ... ។ ពានរ + ឥន្ទ្រ = ... ។ ផល + អាហារ = ... ។ សាសនៈ + ឧបាយ = ... ។ សម្មា + អធិដ្ឋាន = ... ។ ពុទ្ធ + អនុញ្ញាត = ... ។ គុណ + ឧត្តម = ... ។ ជន + អធិបតី = ... ។ ឧបជ្ឈាយ៍ + អាចារ្យ = ... ។ នរ + ឧត្តម = ... ។ ជន + អនុគ្រោះ = ... ។ គាថា ... ផ្ទះខ្ទរ ... ដើមទាំ ... ណាវៃផ ... រទេះគោ ... ។

គុណនាមខ្លះគេប្រើកិរិយា ប៉ុន្តែទីគុណសព្ទជានាមជាច្រើនៗ ឧបមាដូចពាក្យថា : អ្នកក្រ - អ្នកទូល - អ្នកដើរ - អ្នកទៅ - អ្នកមក ... ស័ព្ទជាកិរិយាប្រើជានាម, អ្នកធំ - អ្នកតូច - អ្នកខ្លឹល - អ្នកប្រសប់ -

អ្នកប្រាជ្ញ-អ្នកទៅ... សឹងជាគុណនាមប្រែជានាម, នាមទាំងឡាយនេះហៅជាការកនាម ។

ចូរចុះសំគាល់ជាពាក្យៈ បកតិ, កិត, សមាស, ការកៈ នៅមុខនាមនីមួយៗ :

ឈើគូស (សមាស) ដំណែង... គោខ្មៅ... កាំភ្លើងដៃ...

ផ្លូវ... (បកតិ) បារី... អ្នកស្រែ... សិក្សាធិការ...



ដំណើរ... ប្រវែង... ម្តាយមីង...

គុណោបត្ថម្ភ... ដែក... អ្នកប្រាជ្ញ...

ឪពុកធំ... គជេន្ទ្រ... អ្នកចាំ...

ជំហាន... ម្តាយធំ... ឥន្ទ្រាធិរាជ...

ស្រូវស្រែ... ទឹកឃ្មុំ... រថភ្លើង... មហាសឋ...

អ្នកទ្ធិល... ផ្ទះផ្សារ... បន្ទាត់... ចតុរង្គ...

មនុស្ស... ទំនិញ... ដៃខ្មៅ... នាគរាជ...

សត្វ... ចានគ្រប... កាំបិតកោរ... ពានរ...

តំណ្ដក់... សេះទឹម... ធូសរីស្រុក... យកគ្រូណា... ។

ពាក្យប្ដូររូបព្រោះផ្លាស់អក្សរសឹងជាពាក្យកើតពីព្យញ្ជនៈ វ ។

ឧបមាដូចពាក្យៈ ពិលា = វិលា, ពិសាខ = វិសាខ ។

ចូរផ្លាស់តួ វ ជាតួ ព ឲ្យពាក្យដូចមានតទៅ ៖

វេលា... វេយ្យាករណ៍... វន... ទេវី...

វាក្យ... វ្យាធិ... ហេមវន្ត... ទេវតា... វគ្គ...

វ្យាបាល... វុត្តិ... វេស្សា... វរ = ព្រះ... វារ...

វៀរ... វ្ឫក្ស... វ្យញ្ជនៈ... វាយុ... ប្រថវី...

វ្ឫហស្បតិ... ។

សេចក្ដីចំណាំ – ពាក្យដែលផ្លាស់ វ ជា ព ច្រើនតែពាក្យបាលី និងពាក្យសំស្រ្កត ដែលប្រើក្នុងភាសាខ្មែរ ។

## ៣១- ពាក្យកើតពីអក្សរ ឋ ដ្ឋ ថ ស្ឋ ស្ត ស្ថ

ពាក្យជាច្រើនកើតពីអក្សរ ឋ ដ្ឋ ថ ស្ឋ ស្ត ស្ថ ។ អក្សរ ឋ ដ្ឋ សម្រាប់តែពាក្យដែលជាបាលី ។ អក្សរ ស្ឋ ស្ត ស្ថ សម្រាប់

តែពាក្យជាសំស្រ្កឹត ៗ អក្សរ ថ ប្រែជាពាក្យក្លាយបាលីឬសំស្រ្កឹត ឬជាពាក្យខ្មែរសុទ្ធ ដូចពាក្យៈ បឋម - ឋាន ... ជាបាលី ៗ ប្រថម- ស្ថាន...ជាសំស្រ្កឹត ៗ បឋម - ឋាន ... ក្លាយ ៗ ថន ...បាលី ៗ ស្តន ... សំស្រ្កឹត ៗ ជេដ្ឋ ... បាលី ៗ ជេឞ្ឋ ... សំស្រ្កឹត ៗ

## វិធីហាត់

ចូរផ្លាស់ប្តូរអក្សរ ឋដ្ឋ ជា ថ - ស្ថ - ស្ឋ - ស្ឋ តាមដោយភាពរបស់ពាក្យ ៗ ឧបមាដូចពាក្យៈ បឋវី ផ្លាស់ជាប្រឋវី ៗ

បឋវី ... ឋន ... ថលបថ ... ថូប ...

ហត្ថ ... ឋារ ... ថលយាន ... សាវត្ថី ...

ឧដ្ឋ ... អធិដ្ឋាន ... ឋានានុក្រម ... ថនិកសត្វ ...

ជេដ្ឋ ... មតិដ្ឋាន ... ឋិត ... ថិ (គេខ្ទុយនឹងប្រុស)

ឋិតថេរ ... វត្ថុ ... រដ្ឋ ... ឋានិយ ..

ឋាន ... ជយដ្ឋាន ... ថម្ភ ... គោឃាតដ្ឋាន ...

## ៣៦ - ព្យញ្ជនៈផ្លាស់រូប

## តែសព្ទគន់នៅដដែល

តួអក្សរខ្លះទៀតផ្លាស់រូប តែស័ព្ទរបស់ពាក្យនៅដដែល ដូចពាក្យ: អក្ខរៈ ផ្លាស់ជាអក្សរ, ខត្តិ ផ្លាស់ ជា ក្សត្រ, ខ័យ ជាក្ស័យ, ចក្ក ជាចក្រ, បុត្ត ជាបុត្រ, បញ្ញា ជាប្រាជ្ញា, កទ្ទុបទ ជាកទ្រុបទ, បុញ្ញ ជាបុណ្យ, កិច្ច ជាក្រឹត្យ, បច្ឆិម ជាបស្ចិម, អច្ឆរិយ ជាអស្ចារ្យ, វិជ្ជា ជាវិទ្យា, មជ្ឈិម ជាមធ្យម, ឈាន ជាធ្យាន, ពជ្ឈ ជាពេធ្យ ... ។

ព្យញ្ជនៈផ្លាស់តួដូចមានខាងលើ គឺ: ១ - ក្ខ ផ្លាស់ជាក្ស, ត្ត - ទ្ទុ - ក្ក ផ្លាស់ ជា ត្រ - ទ្រ - ក្រ, ច្ច ជា ត្យ, ជ្ជ ជា ទ្យ, ច្ឆ ជា ស្ច, ញ្ញ ជាណ្យ - ន្យ, ញ្ញ ជា ជ្ញ, ឈ ជា ធ្យ ។

### វិធីហាត់

ចូរផ្លាស់តួព្យញ្ជនៈនៃពាក្យ បើតួនោះគួរគប្បីផ្លាស់ តាមអធ្យាស្រ័យ ។ ១. សមុទ្រ - ពុទ្ធចក្រ... ។

| | | | |
|---|---|---|---|
| សមុទ្ទ... | វីណាស្រត... | អាទិច្ច... | បញ្ញា... |
| ពុទ្ធបក្ក... | មរក្ខ... | អមច្ច... | បុញ្ញ... |
| ខត្ត, ខត្តិយ... | ទក្ខិណា... | បច្ឆិម... | សុញ្ញ... |
| ខេត្ត... | ខេម... | បច្ចាមិត្ត... | កញ្ញា... |
| បុត្ត... | គហាវាស... | អច្ឆរិយ... | អរញ្ញ... |
| អាយុវ័យ... | បច្ចេក... | វិជ្ជា... | ទុក្ខិត... |
| អក្ខរៈ... | បច្ច័យ... | ពេជ្ជ, វេជ្ជ... | មាក្ខធម៌... |
| ខណៈ... | បច្ចូសកាល... | វិជ្ជាធរ... | បិត្ត... |
| កណ្ឌបទ... | កិច្ច...... | មជ្ឈ... | មិត្ត... |
| ខទ្ទី... | ពាក្យសច្ច... | មាណវ... | មជ្ឈិម... |

## ៣៣- អាខ្វាក់អាខ្វិននាំគ្នារត់



មានមនុស្សពិការពីរនាក់ ម្នាក់ខ្វាក់ ម្នាក់ខ្វិន នៅជាប់ឃុំឃាំងទាំងពីរនាក់ ប៉ុន្តែមាស់ដោយខ្លួនពីគ្នា ៗ គេប្រើឲ្យធ្វើការផតអាណាតមេត្តាសោះម្ដោះ ហើយបុរសទាំងពីរគិតថា: ទីនរត់គេចលែងបំរើគេ ៗ លុះដល់យប់គេនាំគ្នាចុះទៅកំពង់ លួចទូកគេជិះចេញទៅ វាអង្គុយឈមមុខទល់គ្នាខំប្រឹងអុំ ៗ ខណៈនោះយប់ងងឹតមើលអ្វីមិនឃើញ វាគិតស្មានថាទូកលឿនទៅមុខហើយ តែទូកនោះនៅ

វិលទៅមកនៅត្រង់កំពង់នោះដដែល ៗ លុះភ្លឺឡើងម្ចាស់ចុះមកឃើញក៏ហៅឲ្យឡើងវិលទៅផ្ទះវិញ ៗ

នៅយូរបានបន្តិចមក អាខ្វាក់អាខ្វិនបបួលគ្នារត់ម្ដងទៀត ហើយពិគ្រោះជាមុនថា: "បើយើងរត់លើកនេះ កុំឲ្យម្ចាស់យើងតាមទាន់ យើងទៅដើរគោកវិញ" អាខ្វាក់ឆ្លើយថា "ទៅផ្លូវម្ដេចបាន បើស្អួតតែខ្វាក់ខ្វិនយ៉ាងនេះ" អាខ្វិនឆ្លើយឡើងថា "ឯងកុំព្រួយ ឯងឲ្យអញជិះលើឯង ហើយអញបង្ហាញផ្លូវឯង" លុះដល់យប់ស្ងាត់ អាខ្វាក់លីកអាខ្វិនដើរចេញទៅដល់ស្រុកមួយ អាខ្វិនប្រទះឃើញខ្ទមគេចាំស្រែមួយ ហើយប្រាប់អាខ្វាក់ថា: "អ៊ុយ អាសំឡាញ់ មានខ្ទមមួយ មានខ្សែត្រមួយបង្អួយ ចង្កើរមួយ ទឹងអណ្ដើកមួយផង" អាខ្វាក់ឮហើយឆ្លើយថា: "អើយ យកឲ្យអស់" ៗ អាខ្វិនថា: "យកធ្វើអ្វីធ្ងន់ឥតអីតើ" អាខ្វាក់ថា: "ធ្ងន់អ្វីឯង ធ្ងន់តែអញទេ, ចេះតែយកទៅ" អាខ្វាក់ក៏ប្រមូលយករបស់ទាំងអស់ ក្នុងខ្ទមនោះមានបាយមួយឆ្នាំងផង ដែលគេដាំទុកនៅជើងក្រាន វាក៏យកទាំងអស់ស្រេច

ហើយតាខ្វិនឡើងជិះលើតាខ្វាក់ទៀត ឯតាខ្វាក់ជាមនុស្សខ្លាំងយករបស់ទាំងនោះទៅបាន ។

## ៣៤-សុភាទន្សាយបានសង្គ្រោះ

ត្រី - កំពឹស - ក្ដាម - ខ្យង ឲ្យរួចជីវិត

ទន្សាយទៅដល់មាត់បឹង ឃើញសត្វទាំងឡាយកំពុងតែបាចទឹក កំបេះស្លឹកឈើដែលមានដង្កូវវារមានស្នាមក្រវេមក្រវាមមកក្លែងធ្វើជាសំបុត្រ ហើយស្រែកប្រាប់សត្វទាំងឡាយនោះថា: "នែបងប្អូនទាំងអស់គ្នាស្ដាប់ខ្ញុំ ! ដ្បិតព្រះឥន្ទ្រឲ្យខ្ញុំនាំសំបុត្រនេះមកប្រកាសប្រាប់អស់អ្នករាល់គ្នាថា: "ព្រះឥន្ទ្រលោកនឹងមក កាប់ដើមត្រុំផ្សំនឹងដើមអក កាប់ក្បាលចចកដកភ្លុកដំរីសារ កាប់ក្បាលតាខ្មៅ ព្រៅ ១ ជាន់គេ វះពោះតាគេ កាត់កតាថ្កាន់ ៗ សត្វទាំងអស់ឮដូច្នោះភ័យណាស់ ផ្អើលនោះឡោះបោលជាន់លើគ្នា ដំរី ក្របី មាស ទន្សោង ខ្លា គេ ស្ទុះបោលទៅជាន់លើតស់



ពួកដែលធ្វើជាទំនប់ ដាច់ខ្ទនជាពីរបីកំណាត់ ធ្លាយទឹកលិច

ស្លាប់អស់សត្វទាំងនោះទៅជាចំណីត្រីនិងអណ្ដើកវិញ ។

តាំងអំពីថ្ងៃនោះមកសត្វទាំងអស់សឹងកោតខ្លាចប្រាជ្ញាទន្សាយ

ហើយហៅថាសុភាទន្សាយទាំងអស់គ្នាអំពីថ្ងៃនោះមក ។



## ៣៥_វិជ្ជាសម្បត្តិ

ហៃសាធុជនទាំងអស់គ្នា ចំណេះវិជ្ជាទាំងសម្ពាយ

មានគុណវិសេសធំទូលាយ គួរយើងរៀបស្តាយកុំខ្លាចធុន់ ។

មិនលំបាកទុកស្រណុកណាក់ ជាជាងមាសប្រាក់សព្វទ្រព្យធន

មិនខ្លាចចោរលួចចោរប្លន់ ទៅគ្រប់ជម្រន់គ្រាន់ជាស្បៀង ។

ឥតកណ្ដៀរកោរកណ្ដុរកាត់ ចាយណាស់មិនបាត់មិនមានល្អៀង

ប្រើច្រើនកើតច្រើនចំរើនទៀត ពីបច្ចុប្បន្នរៀងទៅបរលោក ។

មានសុវិជ្ជាគង់មានទ្រព្យ អ្នកផងមិនស្អប់មិត្តមូលមក

មានមិត្តហើយបុណ្យក៏គង់តែក គ្រប់ទៅបរលោកយានស្ថានសួគ៌ ។

## ៣៦- នាងកង្រីថ្វាយសេចក្ដីស្ងាត់ កំបាំងដល់រទ្ធិសេន

ប្រពាតសួនរួចហើយ ទៅដល់មុខទ្វារឃ្លាំងតូចមួយនៅ ស្លាក់ជាប់សន្លឹកថ្វាយពីកន្ទួនដាខ នាងកង្រីឈប់ស្ងាំងកាំងកាន់ កាំងស្មារតី ហើយភ័យណាស់ ទើបទូលស្វាមីថា: ឃ្លាំងនេះ មានការសម្ងាត់ មាតាខ្ញុំម្ចាស់ហាមផ្ដាច់មិនឲ្យប្រាប់អ្នកណាឲ្យដឹង ថាមានរបស់អ្វីសោះឡើយ ។

នាងវិតចូលទៅជិតស្វាមីហើយទូលថា: ក្នុងឃ្លាំងនេះ នៅលើតុមួយមានពានប្រាក់មួយក្រឡៃមាស ក្នុងពាននោះមានភ្នែកស្រីពីរដណ្ដប់នាក់ ហើយនៅជិតពាននោះមានដបមួយ ក្នុងដបនោះមានថ្នាំដាក់ភ្នែកខ្វាក់ឲ្យជាវិញ ។ បើអ្នកណាខ្វាក់ភ្នែកជ្រះប្រស្រះចេញ គ្រាន់តែរាក់គ្រាប់ភ្នែកក្នុងរន្ធធំទៅវិញហើយលាបថ្នាំនេះទៅ នោះភ្នែកនឹងជាឡើងហើយភ្លឺដូចដើមវិញហោង ។



រិទ្ធិសែនរំភត់សង្កត់ព្រះទ័យអំពីសេចក្ដីទុក្ខសោក ហើយស្ដេចនាំនាងកន្ទ្រីវិលទៅប្រាសាទវិញហោង ។

លុះដល់យប់ ពេលសោយក្រយាស្ងាយ រិទ្ធិសែនបំផឹកស្រានាងកន្ទ្រី ហើយទាំងពួកពលយក្សទាំងអស់ឲ្យស្រវឹងគ្រប់គ្នា លួងលោមឲ្យដេកលក់ទៅ ហើយលបយកកូនសោទ្វារឃុំនាងពីនាងកន្ទ្រីបាន ។ ស្ដេចយាងទៅយកក្អែកនាងពីរដណ្ដប់ មកដបថ្នាំ ហើយទំនង់ដំបងផង ៗ ទើបស្ដេចយាងមកឧបច្ឆម លានាង

ក្រទីដែលកំពុងដេកលក់មិនដឹងខ្លួនសោះនោះ រួចឡើងគង់សេះរត់ទៅ ៗ

## ៣៧- សត្វទុងនឹងត្រី



មានសត្វទុងមួយ ជាសត្វកាន់សក្កាយទិដ្ឋិ ៗ ថ្ងៃមួយវាចេញស្វែងរកចាប់ត្រីជាអាហារ ៗ លុះហែលទៅបានឃើញត្រីក្អកមួយ នៅខាងមាត់ខ្លួន ទុងនោះក៏ចឹកត្រីក្អកនោះបាន ទើបមកគិតថា អាត្មាអញនេះជាបក្សីរូបធំត្រូវតែបរិភោគត្រីធំ ៗ យ៉ាងត្រីរ៉ស់ ត្រីឆ្តោ ត្រីប្រាជាដើម នោះទើបសមនឹងសក្តិយសរូបអញនេះ អាត្រីក្អករូបតូចមួយនេះមិនសមគួរនឹងរូបអញឡើយ គិតហើយទុងក៏លែងចោលបង់ ហើយហែលទៅមុខទៀត បានឃើញត្រីចង្វាក្រៀងមួយ ទុងក៏ចឹកបានឡើងនឹងស៊ី ក៏គិតថា ត្រីចង្វាក្រៀងនេះតូចពេកណាស់ ពុំគួរនឹងរូបអញជាធំ គិតហើយ

ក៏លែងត្រីនោះទៅលបវិ ហើយខំហាលទឹកស្ទូចទៅមុខទៀត ស្ទូចទៅៗ រកត្រីពុំបាន ពេលសោតក៏ចុះទាបល្ងាចបន្តិចផុតពេល ស្ទូច ចុងនោះឯង កើតក៏ឃ្លានអាហារមហិមា ខំស្ទូចរកអាហារ ពុំបានឡើយ ម្ល៉ោះហើយចុងក៏កើតទុក្ខ មុខស្លុបស្លៅកើតក្ដៅចិត្ត គិតស្ដាយអាហារដែលខ្លួនរកបានអំពីព្រឹក ។

## ៣៨ — ស្ត្រីពីរនាក់ដណ្ដើមកូនគ្នា

មានស្ត្រីពីរនាក់មានកូនដូចគ្នា ម្នាក់កូនទើបនឹងស្លាប់ទៅ ម្នាក់កូននៅរស់ហើយពកូនយកទៅផ្ងូតទឹក ។ ឯស្ត្រីកូនស្លាប់នោះ ដើរមកជួបហើយស្រដីថា៖ "កូននាងដូចកូនអញណាស់ នាងអើយ អញសូមបីបកូននាងបន្តិច" ។ នាងម្ដាយក៏ឲ្យកូនទៅ ស្ត្រីនោះ ទទួលយកមកបីបំបៅហើយយកកូនគេដើរទៅលំនៅខ្លួន ។ នាងម្ដាយស្រែកហៅថា៖ "នាងអើយ! នាងយកកូនអញទៅឯណា" ។ ស្ត្រីនោះតបថា៖ "កូនអញទេតើ ម្ដេចក៏មេថាកូនមេ" ។ ម្ល៉ោះហើយឈ្លោះប្រកែកគ្នាទៅវិញទៅមក រួចនាំគ្នាទៅប្ដឹងចៅក្រម ។



ចៅក្រមជំនុំពិភាក្សាកាត់សេចក្តីនេះពុំបាន ទើបនាំស្រ្តីទាំងពីរនោះឡើងទៅ ក្រាបទូលសម្តេចព្រះមហាក្សត្រាធិបតីដោយនូវដំណើរនោះៗ ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ ហើយត្រាស់ឲ្យយកកូននោះទៅដាក់នៅទាំកណ្តាលឲ្យដណ្តើមគ្នា ត្រាស់ថា: បើនរណាដណ្តើមបាន ឲ្យអ្នកនោះយកកូននោះចុះៗ

កាលបើដូច្នោះក្ដី ស្រ្តីទាំងពីរចូលដណ្តើមគ្នា, ឯស្រ្តីស្អប់កូន ចាប់ទាញយួរពុំគិតបាក់បែកហែកដៃជើង ឥតករុណាប្រណី

ៗ

ថាក្មេងឡើយ ៗ ឯម្ដាយយល់ឃើញមេដោះកាំពុះការប្រាប់កូន ចាប់ពុំគិតបាក់បែកឡើយក៏លែងកូនឲ្យបានទៅវាទៅ ៗ ទើបព្រះអង្គមានព្រះបន្ទូលត្រាស់ថា: ព្រោះប្ដន៍លែងកូនឲ្យបានទៅគេនោះ ហេតុដ្បិតអាសូរករុណាកូន ព្រោះស្ដ្រីនោះឯងជាម្ដាយពិតមែន ៗ ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទ្រង់កាត់សេចក្ដីឲ្យបានកូននេះទៅម្ដាយវិញ រីឯមេដណ្ដើមកូនគេនោះ ព្រះអង្គឲ្យផ្ដន្ទាទោស ៗ

## ៣៩-រឿងខ្លាឃ្មុំនឹងដើមពង្រ

ខ្លាឃ្មុំមួយ ទៅដេកនៅក្រោមដើមពង្រ ១ ដើម

លុះដេកលក់បន្តិចទៅ មែកពង្របាក់ធ្លាក់មកត្រូវក្បាល ខ្លាឃ្មុំ



ក៏ភ្ញាក់ក្រោកឡើងម្នីម្នាបាន ក្ដីឈឺក្បាលពន់ពេកណាស់ក៏

ដើរចេញចាកទីនោះ ហើយទឹកចិត្តនឹងដើមពង្រ៍ក៏បង់អាឃាត ។ គ្រាកាលនោះ មានអ្នករទេះម្នាក់បររទេះមកត្រង់ទីនោះ ដួនជាភ្លៅរទេះបាក់ក៏ឈប់ ហើយគាត់ចូលទៅដើរចូលព្រៃ ដើម្បីនឹងកាប់ឈើធ្វើភ្លៅរទេះ ។ លុះដើរៗទៅបានជួបនឹងខ្លាឃ្មុំកណ្ដាលព្រៃ ។ ខ្លាឃ្មុំក៏សួរថា៖ អ្នកបងឯងដើររកអ្វី ចៅនោះក៏ប្រាប់ថា៖ យើងដើររកកាប់ឈើធ្វើភ្លៅរទេះ ខ្លាឃ្មុំបានឱកាសទើបប្រាប់ទៅថា៖ ឈើសម្រាប់ធ្វើភ្លៅរទេះ គ្មានឈើអ្វីជាប់ស្វិតដូចដើមពង្រ៍ទេ ចូរអ្នកឯង ទៅកាប់ដើមពង្រ៍ឯណោះចុះ ។ អ្នករទេះក៏ចូលទៅកាប់ដើមពង្រ៍នោះ តាមខ្លាឃ្មុំប្រាប់ ។ ឯដើមពង្រ៍នោះជាលំនៅនៃរុក្ខទេវតា ។ កាលបើឃើញមនុស្សកាប់លំនៅខ្លួនដូច្នោះ ក៏ចេញមកសួរថា អ្នកកាប់ដើមពង្រ៍ដើម្បីការអ្វី? ចៅនោះប្រាប់ថាយកទៅធ្វើភ្លៅរទេះ ដ្បិតខ្លាឃ្មុំបានប្រាប់ថា ឈើនេះជាប់ល្អណាស់ ។ រុក្ខទេវតាដឹងថាខ្លាឃ្មុំចងគំនុំនឹងដើមពង្រ៍ក៏ប្រាប់ថា បើបានខ្លាញ់ខ្លាឃ្មុំមកលាបនោះ ទើបស្វិតជាប់ល្អបរទៅសប្បាយ បើដូច្នេះចូរអ្នកឯងទៅសម្លាប់ខ្លាឃ្មុំយកខ្លាញ់វាទុកលាបភ្លៅរទេះអ្នកទៅ ។

# ៤០ - ឆ្មាស្រុកនឹងចាបពូក



ឆ្មាស្រុកមួយ ចាបពូកមួយ នៅជាមួយគ្នា ។ ថ្ងៃមួយមានចាបព្រៃហើរមកទំនៅទីជិតចាបពូកនោះ ហើយពោលពាក្យតិះដៀល ចាបនៅក្នុងទ្រុង ចាបក្នុងទ្រុងក៏កើតទោសោះឡើង ទើបជេរប្រទេចទៅចាបព្រៃវិញ ។ ជម្លោះជេរគ្នាទៅវិញទៅមកក៏កើតឡើងតែនឹងប្រប៉ឹកគ្នាពុំបាន ព្រោះមួយនៅក្នុងទ្រុង មួយនៅក្រៅទ្រុង ។ ឯឆ្មាស្រុកបានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏វីងហើយគិតថា “អាសត្វចង្រៃ ហេតុអ្វីក៏មកឈ្លោះប្រកែកនឹងចាបជាសំឡាញ់អញអេះ, បើដូច្នេះអញនឹងជួយចាបជាសំឡាញ់ចុះ” ។ គិតហើយឆ្មានោះចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីជាចម្ងាញ់ ។ “ឱ! អញមិនដឹងជាសាច់ចាបព្រៃមានរសជាតិឆ្ងាញ់ដល់ម្ល៉េះសោះ បើដូច្នេះ ចាប់ដើមតាំងពីថ្ងៃនេះទៅ អញនឹងស្វែងចាប់ចាបព្រៃ

ស្រ័យ" ៗ ឆ្មានោះគិតថ្ងូរហ្វះហើយ ពីថ្ងៃនោះមកតាំងពីស្ទួន លបចាប់ចាបព្រៃតាមស្រ័យជានិរន្តរ៍ ៗ ថ្ងៃមួយឆ្មានោះរកចាប់ចាបព្រៃពុំបាន ដោយញ៉ាំមាត់អត់ពុំបាន ក៏ហែកទ្រុងចូលទៅចាប់ចាបជាសំឡាញ់បរិភោគតាមក្តីប្រាថ្នាហោង ៗ

## ៤១- ល្ពៅនឹងប្លុកទំពក់នៅដៃ

មានអមាត្យមួយនាក់ តែងរក្សាដើមល្ពៅព្រះរាជទ្រព្យព្រះមហាក្សត្រាធិរាជ គាត់កាប់ផ្លែល្ពៅនោះរៀងរាល់ថ្ងៃ បើមានផ្លែណាទុំគាត់បេះទៅថ្វាយស្តេច ៗ គាប់ជួនថ្ងៃមួយមានបុរសម្នាក់យកទំពក់ទៅបេះផ្លែល្ពៅអំពីព្រៃឯទៀត ។ តែបុរសនោះលើទំពក់ដក់ផ្លែល្ពៅដើរទៅទៀបខាងដើមល្ពៅ អមាត្យមើលទៅឃើញបុរសនោះមានទំពក់នៅដៃ នឹងផ្លែល្ពៅ.នៅប្លុក ទើបគាត់ទៅកាប់ផ្លែល្ពៅរបស់គាត់មើល លុះពិនិត្យទៅឃើញខ្វះខ្វះ ទើបគាត់គិតថា: នេះសមអាលើទំពក់បេះផ្លែល្ពៅនេះ ដក់ទៅអំបាញ់មិញនេះឯងជាចោរលួចបេះផ្លែល្ពៅស្តេចមិនខានឡើយ ៗ ទើបអមាត្យក៏រត់ទៅតាម

## ៩៦ — ហ្វាក់ មជ្ឈិមង្គល និង ឧត្តមង្គល



ចៅនោះ ឃើញផ្លែល្ពៅ ទាំចុកចំពាក់នៅដៃ ហើយគោះយកចៅ
នោះទៅក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជ ដោយដំណើរសព្វ
គ្រប់ ៗ ព្រះអង្គមានព្រះបន្ទូលថាកុំគាលគាបវាឡើយ ឲ្យយកផ្លែ
ល្ពៅចៅនេះទៅផ្សាប់ទឹងទង បើវាត្រូវឲ្យចំណាក់អំពីទងនោះមកដី
មើល វាជ្រុះទៅត្រង់ណាឲ្យពិចារណាតាមដោយខ្លួនហេតុនោះ
ហោង ៗ

អមាត្យយកផ្លែល្ពៅទៅផ្គាប់នឹងទងនោះមិនត្រូវឡើយ ព្រះអង្គបង្គាប់ឲ្យទំលាក់មកដី ផ្លែល្ពៅជ្រុះទៅក្នុងថុកកក់ រួចព្រះអង្គឲ្យគេកាយកក់យកផ្លែល្ពៅនោះមកវិញ ។ ព្រះអង្គឲ្យយកផ្លែល្ពៅជ្រុះពីថ្ងៃមុននោះទៅផ្គាប់នឹងទងដដែល មើលឃើញត្រូវមែន ទើបទ្រង់ព្រះរាជទានផ្លែល្ពៅដែលដក់ទៅបោះនោះវិញ បុរសនោះក៏ក្រាបលាយកទំពក់ទងផ្លែល្ពៅទៅបំនៅអាត្មា ។

## ៤២- រឿងសត្វបង្កួយ

មានសត្វបង្កួយមួយ អាស្រ័យនៅលើខ្លោងទ្វារព្រះរាជវាំងនៃព្រះបាទវិទេហរាស្ត្រ នៅក្នុងនគរមិថិលា បង្កួយនោះបានឃើញស្ដេចយាងចេញចូលតាមទ្វារនោះកាលណា ក៏ចុះមកដើរសិរសើផ្ទក់ៗ គឺគំនាប់គោរពព្រះបរមរាជាតែរាល់ៗ កាល ។ ឯព្រះបាទវិទេហរាស្ត្រ ស្ដេចយល់អាការកិរិយាបង្កួយនោះហើយ ក៏ត្រាស់សួរទៅមហោសថបណ្ឌិតពោធិសត្វ ក្រាបទូលតាមហេតុដែលបង្កួយគុនចង្គំចំពោះបរមរាជា ទើបស្ដេចមានព្រះហឫទ័យ

ត្រេកអរនឹងបក្ស័យនោះឯង ហើយទ្រង់ប្រោសប្រាណព្រះរាជទានមាសមួយពៃក្តាម បើកឲ្យនាយពិសេសទិញសាច់ឲ្យបក្ស័យ អាស្រ័យតាមកាលសម័យពីថ្ងៃនោះមក ឯបក្ស័យក៏បាននៅសុខសប្បាយពុំបានខ្វល់ខ្វាយចេញទៅស្វែងរកអាហារឯណាឡើយ ។

## ៤៣ -- អទិន្នបុព្វកៈ

មានព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកៈ នៅក្នុងនគរសាវត្ថី ។ បានជាឈ្មោះដូច្នេះដោយអត្ថថា ព្រាហ្មណ៍នោះជាមនុស្សកំណាញ់ កាញ់សម្បត្តិទុក មិនដែលបរិច្ចាគទ្រព្យ ចេញធ្វើបុណ្យឲ្យទានដល់សមណព្រាហ្មណ៍ និងស្មូមយាចកទាំងឡាយឡើយ ។ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ឈ្មោះមដ្ឋកុណ្ឌលី បានជាមានឈ្មោះដូច្នេះព្រោះកូននោះចំរើនធំឡើងហើយ អទិន្នបុព្វក-ព្រាហ្មណ៍ជាបិតាប្រារព្ធនឹងធ្វើកុណ្ឌលជាគ្រឿងបំពាក់ឲ្យនោះនឹង តែដល់ជាងនឹងធ្វើក្រែងបង់ថ្លៃឈ្នួល ទើបព្រាហ្មណ៍យកមាសមកដំដោយខ្លួនឯងធ្វើកុណ្ឌល ។ លុះចំណេរមក មដ្ឋកុណ្ឌលី

នោះមានជម្ងឺឈឺ គឺរោគលឿង ។ ទើបនាងព្រាហ្មណីនិយាយនឹងប្តីថា: អ្នកអើយកូនយើងស្គម កើតលឿងឈឺរីងរៃយ៉ាងនេះ គួរអ្នកទៅរកគ្រូពេទ្យមកមើលមករក្សា, ឯព្រាហ្មណ៍ជាអ្នកខ្វាបបង់ខាតសម្បត្តិ ក៏ធ្វើព្រងើយកន្តើយមិនអើពើក្នុងការរកគ្រូមករក្សាកូនឡើយ ។ ឯរោគកូននោះរឹងរឹតតែឈឺធ្ងន់ឡើង ព្រាហ្មណ៍យល់អាការរោគកូនកាន់តែឈឺធ្ងន់ ទើបគិតថា « កូនអញនឹងទុកឲ្យនៅក្នុងផ្ទះនេះយល់ជាពុំបាន ក្រែងពួកញាតិមិត្តទាំងឡាយគេចូលមកសួរជម្ងឺ គេនឹងឃើញទ្រព្យសម្បត្តិអញ ហើយគេនឹងមកក្លួនវិប្តសុំអញ » ។ ព្រាហ្មណ៍នឹងប្រពន្ធនាំគ្នាសែងគ្រែកូនចេញមកដាក់នៅល្វែងតាកផ្ទះ ។ ឯចៅមដ្ឋកុណ្ឌលីកុមារនោះ លុះរោគកំរើកខ្លាំងឡើងហើយ ក៏ដល់នូវកាលកិរិយាក្ស័យក្នុងកាលនោះហោង ។

## ៤៤- ស្ទូចត្រី

គូកនពីរនាក់ គឹមនឹងសាន រៀនទៅសាលាជាមួយគ្នា



ថ្ងៃឱកាសថ្ងៃព្រហស្បតិ៍ ក៏ទៅស្ទូចត្រីនៅមាត់ស្ទឹងសែន ។ លុះព្រឹកឡើងវានាំគ្នាចេញទៅពីព្រលឹម ដៃមានសម្លៀកបំពាក់ចាស់ៗ មួកធំដើម្បីបាំងចំហាយព្រះអាទិត្យផង ។ ទៅគឹមលីដងសន្ទូចមួយ ដៃមានខ្សែថ្មីសន្ទូចកំសួលទីងប្រអប់ស៊ីវិឡាតដាក់នុយ ។ ចៅសានកាន់ល្អីស្បៀងអាហារ ។ ក្មេងទាំងពីរនាក់ទៅឈប់នៅកន្លែងមួយនាមាត់ទឹកដែលមានម្លប់ល្អ វាស្ទូចនៅទីនោះ ។ ជម្សីគ្មានត្រីមកស៊ីសោះ គឹមនឹងសានពុំកើនកំរើកខ្លួនឡើយក្រែត្រីផ្អើល ។ មួយស្របក់មានត្រីប្រែនហែបហែលនានាទឹក ។ កំសួលសន្ទូចក្រញាលឡើងម្ដងៗ គឺត្រីស៊ីសន្ទូចរាំងផងសន្ទូចឡើងបានត្រី ។ មិនយូរ

ប៉ុន្មានវាបានត្រីពេញគ្រែកវាសប្បាយចិត្តក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ។ ម្ដាយវាទាំងពីរនាក់ក៏មានសេចក្ដីរីករាយ ហើយយកត្រីធ្វើម្ហូបស៊ីបាយ ។

## ៤៥- ផ្លែមង្ឃុត

សានទីនិងខ្ញុំកាន់ដៃគ្នាដើរលេង ។ ដើរបានបន្តិចទៅវា



ប្រទះផ្លែមង្ឃុតមួយនៅកណ្ដាលផ្លូវ ។ សាននិយាយថា: ផ្លែមង្ឃុតនេះត្រូវបានអញ ព្រោះអញបានឃើញមុន ។ ខ្ញុំថាត្រូវបានអញទេ ព្រោះអញរើសបាន ។ ក្មេងទាំងពីរនាក់បេះគជជែកទៀបតែប្រវាយប្រតប់គ្នា ។ មានក្មេងម្នាក់ទៀត ឈ្មោះសារី មកដល់ទីនោះ វាឈរនៅចន្លោះក្មេងទាំងពីរ ហើយសួរកដើមហេតុ រួចក៏យកកាំបិតបត់ពីហោប៉ៅអាវ វាពុះមង្ឃុតជាពីរ

ហើយនិយាយថាៈ សំបកមង្ឃុតមួយចំហៀងនេះ ត្រូវបានទៅសាខ ដែលបានឃើញមុន ឯសំបកមួយចំហៀងនេះទៀតត្រូវបានទៅខ្ញុំ ដែលបានរើស, រីខ្លួនអញ ដូចជាគេថាតែធ្វើការអ្វីត្រូវមានឈ្នួល, បើដូច្នេះ អញត្រូវបានសាច់ ជារួចហើយ សារីពមសាច់មង្ឃុតទៅៗ

## ៤៦ - ដេញចាប់ចោរ ៗ ចាប់វិញ



បុរសមួយនាក់ដេកលើសាលា ៗ ការចោរម្នាក់លួចគោគេ

ដេញល្បូទៅ ៗ បុរសដេកលើសាលា ក៏ស្ទុះលោតចុះទៅ ចាប់បានអាចោរ ៗ លុះម្ចាស់គោតាមទៅទាន់ អាចោរស្រដី ប្រាប់ទៅថា៖ ចៅនេះឯងលួចគោអ្នក ៗ ឯបុរសដេកលើសាលា ឆ្លើយឡើងថា៖ ចៅឯងលួចគោគេអញចាប់ចៅឯងបាន ម្ដេចចៅមក ថាអញវិញ ៗ ម្ចាស់គោយល់ថាប្រកែកគ្នាដូច្នោះហើយ ទឹងចាប់តែ ម្នាក់ឯងខ្លាចក្រែងពុំមែនចោរនោះ ទើបចាប់មនុស្សទាំងពីរទៅប្ដឹង ចៅក្រមឲ្យជំនុំជំរះ តាមពាក្យបណ្ដឹងទាំងសងខាង ៗ ចៅក្រម ពិចារណាកាត់សេចក្ដីនោះពុំបានឡើយ ក៏នាំឡើងទៅក្រាបទូល ក្សត្រាធិរាជដោយដំណើរនោះ ៗ ព្រះអង្គទ្រង់ព្រះចិន្ដាត្រាស់ បង្គាប់ឲ្យយកមនុស្សទាំងពីរនាក់នេះទៅបង់ឲ្យមូសខាំ ហើយឲ្យ អមាត្យទៅលបចាំស្ដាប់ពាក្យចៅទាំងពីរនោះ ៗ ចៅដែលដេក លើសាលាពោលរអ៊ូថា៖ បទតែឯង លួចគោគេទើបគេបង់អញឲ្យ មូសខាំ ៗ អាចោរថាអញលួចតែអញ ហេតុអ្វីក៏ទៅចាប់អញ

ព្រោះតែចាប់អញ ទើបគេបានអញមក  អមាត្យគត់ពាក្យចៅចាំង៏ពីរ នោះ ហើយនាំឡើងទៅថ្វាយក្សត្រាធិរាជ  ព្រះអង្គបង្គាប់ឲ្យពិន័យ អាចោរមួយជាបួន  គឺយកទ្រព្យដើមចេញ  ហើយចែកក្រយាពិន័យ ជាភាគបី  ភាគមួយបានទៅម្ចាស់គោ  ភាគពីរបានទៅចៅដែល ចាប់បានខ្លួនចោរនោះ ។

ការផ្សាយរបស់
បណ្ណាគារ គិម-សេង
លេខ ២២៣ វិថីព្រះមុនីវង្ស
ភ្នំពេញ

តម្លៃ